លី-ធាមតេង

Mr Watanabe

# សរសេរតាមសូត្រ

## ពន្យល់

សំរាប់

## សិស្ស-គ្រូ

ក្នុងការប្រឡងចូលថ្នាក់ទី ៦ មធ្យមសិក្សា



បណ្ណាគារ សេង-ងួនហួត ភ្នំពេញ

CA9

លី · ធាមតេង

# សរសេរតាមសូត្រ

ពន្យល់

# DICTEE EXPLIQUEE

សំរាប់

## សិស្ស-គ្រូ

ក្នុងការប្រឡងចូលថ្នាក់ទី ៦ មធ្យមសិក្សា

ចេញផ្សាយពី

បណ្ណាគារ

សែង · ងួន · ហួរ

លេខ ៦៣ វិថីព្រះបាទចន្ទរាជា

ភ្នំពេញ

១៩៥៨

# អារម្ភកថា

សរសេរតាមសូត្រ ឬ អនុវាក្យ ជាកិច្ចការពិសេសមួយសំរាប់អ្នកសិក្សាគ្រប់ថ្នាក់ ។ គឺនៅក្នុងមុខវិជ្ជានេះហើយ ដែលណែនាំសិស្សឲ្យចេះសរសេរបានត្រឹមត្រូវ ទាំងអក្ខរាវិរុទ្ធរបស់ពាក្យ និងរបៀបត្រឹមត្រូវតាមវេយ្យាករណ៍ ។

នៅក្នុងសៀវភៅនេះ ខ្ញុំបានជ្រើសរើសអត្ថបទថ្លែក ៗ ពីអ្នកនិពន្ធដទៃខ្លះ និងសរសេរឡើងដោយខ្លួនឯងខ្លះ ដែលសឹងតែមានពាក្យពេចន៍គ្រប់គ្រាន់ជួយផ្ដល់ប្រយោជន៍ ក្នុងការរៀនសូត្រដល់បណ្ដាសិស្សនៅថ្នាក់ទី ៦ និង នៅថ្នាក់ឧត្ដមដ្ឋានដែលត្រូវប្រុងប្រៀបបន្តវិជ្ជា ទៅមធ្យមសិក្សាទៀត ។ នៅខាងចុងអត្ថបទនិមួយ ៗ ខ្ញុំបានធ្វើជាសេចក្ដីពន្យល់ពីអត្ថន័យពាក្យមួយម៉ាត់ ៗ , ពីអក្ខរាវិរុទ្ធរបស់ពាក្យ និងវាក្យសព្ទ ដែលសិស្សត្រូវការចំណាំទុក កុំឲ្យមានការភ័ន្តច្រឡំតទៅ ។

ពិតមែនតែក្នុងសៀវភៅនេះ មិនមានអត្ថបទអនុពាក្យច្រើន ដល់ទៅពប់រយ តែខ្ញុំសង្ឃឹមថា ក៏គង់បានជាជំនួយមួយយ៉ាងសំខាន់របស់អ្នកត្រូវការជាមិនខាន ។

ទីបំផុត ខ្ញុំសូមថ្លែងសេចក្ដីគោរពយ៉ាងសុទ្ធចិត្តចំពោះអស់លោកអ្នកនិពន្ធទាំងឡាយ ដែលខ្ញុំបានដកស្រង់យកស្នាដៃរបស់លោកមកដាក់ក្នុងសៀវភៅនេះ ។

ភ្នំពេញ, ថ្ងៃទី២៣ មករា ១៩៥៨

អ្នកនិពន្ធ

# ១ - បវេសនកាល 第 ១

ថ្ងៃនេះ, បើគេសង្កេតពីចម្ងាយមក គេឃើញមានមនុស្សអ៊ូអរនៅមុខសាលារៀនប៉ែកពីជម្ពូតា ៗ គឺជាបវេសនកាល ។ សិស្សតូចធំប្រដាប់ដោយសំលៀកបំពាក់ស្អាត ៗ កាន់សៀវភៅថ្មី ៗ នៅដៃ ហើយដើរតម្រង់ចូលទៅគ្រឹះស្ថានសិក្សារបស់ខ្លួន ៗ នៅក្នុងសួនពីមុខសាលាដែលមានផ្កាពណ៌ផ្សេង ៗ ជាលំអ មានសិស្សច្រើនរូបឈរនិយាយគ្នាសើចក្អាកក្អាយ ព្រោះគេបែកគ្នាអស់រយៈវេលាជាងពីរខែហើយ ៗ សូរនិយាយនេះ បង្កើតបានជាសព្ទទ្រហឹងអឺងកង ដូចហ្វូងឃ្មុំកំពុងហើរត្រួតត្រាជុំវិញសំបុក ។ ×

ចលនា (Recouvrement) រស់រវើកនេះ កើតមានចំពោះតែសិស្សចាស់ ៗ ទេ ចំណែកអ្នកទើបតែមកចូលរៀនដំបូងក្នុងថ្ងៃនេះវិញ ពុំសូវរីករាយដូចគេសោះ ដ្បិតនៅក្នុងចិត្តគេ បេះតែមានសេចក្តីបារម្ភជានិច្ច ដោយគេពុំទាន់ស្គាល់អ្នកណាជាមិត្តនៅ

trouve inquiet

ទៀយ ៗ ឯពពួកគ្រូ តែចុះឡើងខំរៀបចំធ្វើពិធីគោរពទង់ជាតិ ៗ គេឈរតម្រៀបគ្នាជាជួរ ៗ ដោយកិច្ចបញ្ជានៃគ្រូម្នាក់ សិស្សទាំងនោះបន្លឺឡើងនូវបទនគររាជយ៉ាងគ្រលួច នៅពេលដែលទង់ជាតិ បានបង្ហូតឡើងខ្ពស់ត្រដែតនៅលើចុងដងទង់ ហើយកាច់កែវកើរពើតតាមចង្វាក់ខ្យល់ព្រះពាយ ៗ រួចកិច្ចនេះហើយ គេដើរទាំងជួរ ៗ តម្រង់ទៅថ្នាក់រៀនរៀង ៗ ខ្លួន ៗ

ឱកាសនេះ គួរចាត់ទុកជាឱកាសមួយយ៉ាងឧឡារិក នឹងជាអនុស្សាវរីយ៍ របស់សិស្សគ្រប់រូបក្នុងវេលាដែលសិស្សនឹងគ្រូបានជួបមុខគ្នាជាថ្មីទៀត ៗ

លី - ណាមគេង

ក- ពន្យល់ពាក្យ

បវេសនកាល : ថ្ងៃចូលរៀនដំបូង, (La rentée) ៗ

គ្រឹះស្ថានសិក្សា : ផ្ទះ ឬ លំនៅជាកន្លែងរៀនសូត្រ ៗ

រយៈពេល : រវាងពេល (la durée) ។

ចលនា : ការកំរើក (mouvement) ។

នគររាជ : ឈ្មោះភ្លេងប្រចាំជាតិរបស់ខ្មែរយើង ។

យ៉ាងឧឡារិក : យ៉ាងអឹកធឹក, យ៉ាងកិត្តិយស ។

អនុស្សាវរីយ៍ : ជាទីរលឹកមិនភ្លេច (souvenir) ។

ខ- អក្ខរាវិរុទ្ធ

អ៊ូអរ (មាន រ នៅចុង)

ប្លែក (អក្សរ ប មិនមែនអក្សរ ផ ទេ)

លំអ (ឥតមាន រ ទេ)

រយៈពេល (ត្រូវមានយុគលពិន្ទុពីមុខអក្សរ យ)

ហើរ (មាន រ នៅចុង)

គ- ពាក្យស័ព្ទ

លំអ គុ. (ផ្ទះនេះមានគ្រឿងលំអជាច្រើន)

អំណរ ន. (ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក)

កំពុង កិ. (ខ្ញុំកំពុងធ្វើការ)

កំពង់ ន. (គេទៅទិញត្រីឯមាត់កំពង់)

បារម្ភ កិ. (ខ្ញុំបារម្ភណាស់ពីរឿងនេះ)

អារម្មណ៍ ន. (គេអង្គុយបណ្ដែតអារម្មណ៍)

ជួរ ន. (ដើមស្វាយតម្រៀបគ្នាជាជួរ)

ឆ្គួ គុ. (ក្មេងនេះមានឫកពាឆ្គួណាស់)

ចង្វាក់ ន. (ច្រៀងឲ្យត្រូវតាមចង្វាក់ភ្លេង)

សង្វាក់ ន. (សង្វាក់ជាម្ហូបពិសេសនៅខេត្តបាត់ដំបង)

---

## ២- អ្នកតាដង្កោតាមិល

នៅពេលជិតថ្ងៃត្រង់ កងរទេះបានបរដល់ដំបន់មួយ ហៅថាដង្កោតាមិល ដែលជាទីខ្ពស់មួយ ទឹករដូវវស្សាមិនដែលលិចទេ ។ បានជាអ្នកផងហៅថា ទួលដង្កោតាមិល

ដូច្នេះ ព្រោះទួលនេះមានដើមដង្កោមួយធំខ្ពស់ដូចធ្យូង តែកំបុតឥតចុងដោយរន្ទះបាញ់ផ្តាច់ជាយូរមកហើយ ។ រុក្ខជាតិនេះមានស្លឹកនៅតែគ្រប់ប្រគាបប៉ុណ្ណោះ ។ នៅជាប់នឹងដើមដង្កោនេះ មានដើមអំពិលមួយធំណាស់ដែរ ដែលបែកមែកសាខា ហាក់ដូចជាគ្របបាំង កុំឲ្យកូនខ្ទមតូចមួយដែលនៅឯបនឹងគល់ ត្រូវកំដៅព្រះអាទិត្យឡើយ ។ នៅក្នុងខ្ទម មានបដិមាមួយធ្វើពីថ្មខៀវប្រផេះ ។ រូបនេះមានបបូរមាត់ញាក់សម្បែស ហើយមានផ្កាំងជាតិ រុំព័ទ្ធជាក្រមា ។

រូបចម្លាក់នេះ ជារូបអ្នកតាដង្កោតានិលដែលមានឫទ្ធានុភាពខ្លាំងពូកែណាស់ ។ អ្នកដំណើររទេះ កាលបើបានដល់ទួលនេះហើយ គេរមែងឈ្លាតកាច់មែកឈើ, ប្រួចស្រា, សែនបាយទឹក, ចំណីចំណុក ដើម្បីសូមលាភ, សូមជ័យពីលោកអ្នកតា ។

ឡូ - ហាប

## ក- ពន្យល់ពាក្យ

កង់រទេះ : ហ៊ុងរទេះ, រទេះមួយហ៊ុង ។

មែកសាខា : មែកសន្ធឹងទៅសងខាងមានម្លប់ត្រជាក់ ។

បដិមា : រូបសំណាក, រូបចម្លាក់ដំណាងអ្វីមួយ ។

ធ្លាក់សម្បែស : ធ្លាក់ស្តែស, ធ្លាក់ចេញគេកលរបូត ។

ផ្ទាំងវាតី : ផ្ទាំងក្រណាត់ក្រហមពណ៌ឈាម ។

បុណ្ណានុភាព : ចេស្តាបារមី, បុណ្ណអំណាច ។

### ១- អក្ខរាវិរុទ្ធ

ប្រគាប (សរសេរ គ ដាក់ស្រៈ អា)

ភ្ជាប់ (សរសេរ ភ ដាក់ជើង ជ )

ឯប (សរសេរអក្សរ ឯ ស្រៈពេញតួ )

បបូរ (មាន រ នៅចុង )

ប្រប្ប (សរសេរ ប មិនមែន ជ ទេ )

លាភ (ត្រូវប្រកបនឹងអក្សរ ភ)

ជ័យ (ដាក់សំយោគសញ្ញាលើ ជ)

គ– ពាក្យស័ព្ទ

លិច កិ. (ទឹកលិចពេញព្រៃ. ថ្ងៃលិចចុះ)

លេច កិ. (លេចឃើញ. លេចឡើង)

លាភ ន. (ខ្ញុំមានលាភបានបំណាច់ប្រាក់ ១ ម៉ឺន)

លាប កិ. (ជាងលាបផ្ទះឡល្អ)

---

## ៣ – ប្រាសាទនគរវត្ត

នគរវត្តជាប្រាសាទមួយល្អជាងគេ បណ្ដាប្រាសាទទាំងឡាយនៅអង្គរ ។ គេកសាងក្នុងសម័យនៃវិទ្យាសាស្រ្តកំពុងចំរើនបរិបូណ៌ ព្រោះមានទ្រង់ទ្រាយល្អ នឹងទ្រង់សក្ដិសមនៃភាពពាង លេចស្រស់ឡើងក្នុងកាលគេចូលទៅជិត ហើយគេអាចយកទៅទុកជាទីវិស្វកម្មនៃប្រទេសអស្ចារ្យបាន ។

ប្រាសាទនគរវត្តនេះ ព្រះបាទសូរ្យវរ្ម័នទី ២ ស្តេចសាងក្នុងរវាងសតវត្សទី ១៧ នៃពុទ្ធសករាជ ដើម្បីឧទ្ទិសថ្វាយព្រះវិស្ណុ, ) លុះដល់ស្តេចទិវង្គតទៅ គេថ្វាយព្រះនាមព្រះអង្គថា "ព្រះបរមវិស្ណុលោក" ។

Mort

ស្ពានថ្មធំមួយ ចូលពីទិសបស្ចិម កាត់ឆ្លងស្រះបោក្ខ-រណី រហូតទៅដល់ទ្វារធំខាងលិច នៃប្រាសាទនេះ ដ៏មានបង្កាន់ដៃនាគ ប្រកបដោយសីហៈធំសំបើម, ងើយមុខស្ងើន, តែឥឡូវនេះបាក់បែកស្ទើរតែអស់ហើយ ។ កាលណាគេចូលទៅដល់ក្លោងទ្វារធំខាងលិចនេះ ទ្រង់ទ្រាយរុងរឿងថើតឆាយ, ទ្រង់ទ្រាយមានឫទ្ធិតេជះនៃប្រាសាទនេះ អាចធ្វើឲ្យអ្នកដំណើរស្ញប់ស្ញែងក្នុងចិត្ត ។

ប៉ាង - ខាត់

## ក-ពន្យល់ពាក្យ

វិទ្យាសាស្ត្រ : ក្បួនច្បាប់នៃវិជ្ជា, ការត្រិះរិះវិជ្ជា (science) ។

វិស្វកម្ម : ការសាងទូទៅ, កំពើគ្រប់យ៉ាងខាងជំនាង ។

ប្រទេសអស្តង្គត : ពួកប្រទេសប៉ែកខាងលិច (Occidental) ។

សតវត្ស ឬ សតវត្សរ៍ : រយៈកាល ១០០ ឆ្នាំ (siècle) ។

ព្រះវិស្ណុ : ឈ្មោះទេព្តាមួយអង្គខាងសាសនាព្រាហ្មណ៍ ។

ទិវង្គត : សោយវិលាល័យ, សុគត ។

បស្ចិម : ទិសខាងលិច ។

ស្រះបោក្ខរណី : ស្រះដែលមានដាំឈូក ។

សីហៈ : សត្វសិង្ហ (រូបសត្វសិង្ហ) ។

ពុទ្ធិតេជះ : បុណ្យបារមី, ពុទ្ធអំណាច ។

១- អក្ខរាវិរុទ្ធ

បណ្ដា (ឥតមាន រ ទេ)

នាគ (សរសេរប្រកបនឹង គ)

ស្ទើរ (មាន រ ឯស្ទើគ្មាន រ ទេ)

ក្លោងទ្វារ (សរសេរ ក ដាក់ជើង ល)

តេជះ (សរសេរ ត ដាក់ស្រៈ អេ)

គ- ពាក្យស័ព្ទ

ក កិ. (គេកសាងសាលាថ្មីមួយ)

ក៏ និ. (ខ្ញុំក៏មានលុយ គេក៏មានលុយ)

ករ ន. (អមាត្យលើកករប្រណម្យព្រះរាជា)

សក្តិ ន. (សក្តិសមល្អ, អ្នកមានយសសក្តិ)

សាក់ កិ. (ខ្មែរខ្លះសាក់ពេញទាំងខ្លួនដាយ័ន្តគាថា)

ស័ក ន. (ឆ្នាំនេះជាឆ្នាំរកានព្វស័ក)

ATO Eng

# ៤- វិធីព្រះអង្គអេង

ព្រះអង្គអេង! ព្រះអង្គអេង! ជាឈ្មោះវិធីមួយដែលខ្ញុំចាំបានយ៉ាងស្គាល់ ៗ វិធីនេះមានមនុស្សកុះករលើសវិធីនានា ក្នុងរាជធានី ៗ នៅលើខឿនផងតាំងសងខាងមានប្រុស-ស្រីក្មេង-ចាស់សញ្ចរទៅ-មកឥតឈប់ ៗ បើគេគយគន់ពីចម្ងាយមក ឃើញតែក្បាលមនុស្សខ្មៅមីរ ហើយមានសភាពមិនរាបស្មើ ប៉ុនដូចជារលកទឹកគគ្រាំគគ្រេងក្នុងផ្ទៃជល-ធារ ៗ ហ្វូងនារីដែលតុបតែងប្រាណយ៉ាងស្រស់បំព្រង, បញ្ចេញគន្ធពិដោរក្រអូបសាយពីពង់កាយ ដើរខ្វៃងខ្វាត់គេទិញគ្រឿងប្រណីត មានម្សៅនិងទឹកអប់ជាដើម ៗ

ចំណែកហ្វូងបុរស ក៏សំអិតសំអាងកាយមិនឲ្យចាញ់ប្រៀបនារីទាំងនោះដែរ ៗ គេដើរបញ្ចេញទឹកមុខស្រស់ប្រិមប្រិយ៍សឲ្យឃើញថាជាអារ្យជនក្នុងសតវត្សនេះ ៗ នៅចំកណ្ដាលវិថីដែលបែកចេញពីគ្នាជាបួន មានក្តាក់ផ្ទះអាក្សា

ឈរនៅចាំធ្វើបញ្ជាលើចរាចរណ៍ ដើម្បីជៀសវាងកុំឲ្យមាន គ្រោះថ្នាក់ដល់ប្រជាជន ទឹងរថយន្តនានាឲ្យបត់ទៅតាមផ្លូវ ឯកទិស ។

វិថីព្រះអង្គអេង គួរចាត់ទុកជាវិថីមួយដ៏ល្អឯកក្នុងរាជធានី យើង ប៉ុន្តែបើសង្កេតឲ្យច្បាស់លាស់ទៅ ឃើញច្រើនតែ ជនបរទេសទេ ដែលនៅតាំងទីលក់ដូរតាមរបៀងផ្ទះទឹងលើ ខឿនវិថីនេះ ។ ឯបណ្ដាជនខ្មែរយើងច្រើនតាំងខ្លួនជាអ្នក ដើរទិញ សព្វកាលសព្វវេលា ។

លី - ណាមតេង

ក- ពន្យល់ពាក្យ

វិថី : ផ្លូវធំៗ ដែលនៅក្នុងទីក្រុង (la rue) ។

រាជធានី: ទីក្រុងធំ, ក្រុងដែលស្ដេចគង់នៅ (la capitale) ។

សញ្ចរ : ដើរទៅ-មក, ធ្វើដំណើរតាមផ្លូវ ។

ជលធារ : ផ្លូវទឹក, ទន្លេឬសមុទ្រ ។

គន្ធពាដារ : កូនក្រមុំ ។

គ្រឿងប្រណីត : គ្រឿងទំនើបដ៏មានដម្លៃ (luxe) ។

អារ្យជន : ជនស៊ីវិល័យ, មនុស្សចំរើន (Civilisateur) ។

អារក្ខា : អ្នករក្សា, អ្នកត្រួតត្រាឲ្យសុខ (Police) ។

ធ្វើបញ្ជា : ធ្វើសេចក្តីបង្គាប់ (Commander) ។

ចរាចរណ៍ : ការដើរ, ការត្រាច់ទៅ-មក (Circulation) ។

ឯកទិស : ទិសតែមួយដែលតម្រូវឲ្យទៅ (Sens unique) ។

ជនបរទេស : អ្នកប្រទេសដទៃ (étranger) ។

បណ្តាជន : ចំណោមមនុស្សនៅក្នុងប្រទេស (population) ។

១– អក្ខរាវិរុទ្ធ

កុះកុំ (កុំសរសេរ កុសកុំ)

នានា (កុំសរសេរនា ៗ ឲ្យសោះ)

មីរ (សរសេរមាន រ នៅខាងចុង)

ផលធារ (កុំសរសេរ ផល់ធា)

ប្រណីត (សរសេរស្រះ អី លើណ)

ប្រឹមប្រីយ៍ (កុំសរសេរ ប្រិមប្រី)

ទិស (កុំសរសេរ ទឹស)

គ- វាក្យស័ព្ទ

ឥដ្ឋ ន. (ផ្ទះឥដ្ឋ. កំពែងឥដ្ឋ)

ឥត និ (និយាយនេះ ឥតបានការទេ)

ស កិ. (សឲ្យឃើញនូវសេចក្ដីក្លាហានរបស់ខ្មែរ)

ស កិ. (ពូព្រហ្មសត្រីក្នុងបឹង)

ស ន. (ក្រដាសសដូចសំឡី)

សរ ន. (ព្រះរាមថ្លែងសរបាញ់យក្ស)

---

## ៥ - ផ្ទះកំណើត

ផ្ទះកំណើតដែលជាកេរ្តិ៍ពីឪពុកខ្ញុំ សង់នៅក្បែរផ្លូវមួយក្នុងទីជនបទ ។ គេហស្ថាននេះសង់ដោយឈើប្រក់ក្បឿង

ដែលផ្កាសំពណ៌ក្រហមនៅជាពណ៌ដីប្រផេះ បង្ហាញឲ្យគេដឹង ថា ផ្ទះនេះសង់ជាយូរឆ្នាំណាស់មកហើយ ។

គ្រាណាខ្ញុំបានធ្វើដំណើរទៅកាន់លំនៅនេះម្តង ៗ ខ្ញុំឈានជើងដើរចូលដោយអាក់អួលចិត្តក្រៃលែង ដ្បិតមានវត្ថុជាអនុស្សាវរីយ៍ជាច្រើនសំរាប់ដាស់ស្មារតីខ្ញុំឲ្យរលឹកឃើញដល់រូបលោកឪពុកខ្ញុំដែលបាត់បង់ជីវិតទៅជាយូរយារហើយ ។ ពីមុខផ្ទះ, របងអម្ពិលទឹកដែលខ្ញុំធ្លាប់ឃើញឪពុកខ្ញុំកាត់ដូរមជាញឹកញាយពីគ្រាដែលលោកគង់ជីវិតនៅឡើយនោះ ឥឡូវនៅតែស្រស់ញញឹមដដែល ។ *ដើមដូង, ស្វា, ខរ, ក្រាំបែកទៀប ដុះដង្ហែគ្នាតាមរបង ដែលជាស្នាដៃរបស់ខ្មោចឪពុកខ្ញុំបណ្តុះបណ្តាំនោះ, កំពុងបក់ព្រោយស្លឹកតាមកម្លាំងវាយោពាក់បេះស្រដីសួរសុខ-ទុក្ខ ឬ សំម្តែងស្វាគមន៍ចំពោះរូបខ្ញុំដែលទើបនឹងមកដល់ ។ ខ្ញុំឈានជើងជាន់ឡើងលើកាំជណ្តើរប្រកបដោយទឹកចិត្តក្រៀមស្ងួតក្រៃលែង ។

គឺជាទីនេះហើយ ដែលខ្លួនខ្ញុំធ្លាប់បានជ្រកក្រោមយ៉ាងសែនសុខជាមួយអ្នកដ៏មានគុណឥតរង្គៀសឡើយ ។ អភ័ព្វអ៊ុហា ! ក៏ពេលនេះខ្ញុំមិនបានយល់ភក្ត្របុព្វការីជនរបស់ខ្ញុំដូចពីកាលមួយឆ្នាំមុនទៀត ? លោកអញ្ជើញទៅណា ? ទៅចោលខ្ញុំឲ្យនៅរក្សាផ្ទះកំណើតខ្ញុំដ៏ក្រៀមក្រំ ។

លី-ធាមតេង

ក- ពន្យល់ពាក្យ

គេហស្ថាន : លំនៅ, ផ្ទះ, កន្លែងជ្រកនៅ ។

ទីជនបទ : ទីដែលនៅឆ្ងាយពីក្រុងធំ ។

វាយោ : ខ្យល់, ព្រះពាយ, វាតា ។

ស្វាគមន៍ ដំណើរល្អ, ប្រសិទ្ធឲ្យបានដំណើរសុខ (Bienvenue)

បុព្វការីជន : បុគ្គលដែលបានទំនុកបំរុងពីមុនមក (មាតាបិតា) ។

១- អក្ខរាវិរុទ្ធ

ក្បែរ (មាន រ នៅខាងចុង)

ផ្លាស់ (សរសេរ ផ ជើង ល ស្រៈអា ទឹង ស សង្កត់)

ផាស់ (សរសេរ ផ ស្រៈអា ទឹង ស សង្កត់)

យូរយារ (យូ មាន រ, យា មាន រ)

ដង្ហែ (គ្មាន រ ទេ)

ហ្ន៎ (សរសេរ ហ ជើង ន កាកបាទពីលើ)

គ- ពាក្យស័ព្ទ

កេរ្តិ៍ ន. (ទ្រព្យធនដែលកេរ្តិ៍ពីឪពុកម្ដាយ)

កេរ ក. (ស្រីខ្វះចូលចិត្តនិយាយកេរគេ)

ទៀប ន. (ទៀបមួយដើមផ្លែយ៉ាងច្រើន)

ទៀប ន. (គេដាក់នំក្នុងចានទៀប)

ទៀប អា ទិ. (ព្រះអាទិត្យទៀបនឹងអស្ដង្គត)

ទាប គុ. (សង្ឃ័ះទាបក្បែរដី)

---

# ៦ - វិស្សមកាល

ជួនជាសញ្ញាបានបន្លឺសូរឡើង ឲ្យសិស្សទាំងឡាយដឹងថាជាពេលឈប់សំរាកចំនួនដប់ប្រាំនាទីមកដល់ហើយ ។ គ្រូអនុញ្ញាតឲ្យសិស្សចេញពីក្នុងថ្នាក់ ទៅលំហែខ្លួនឯក្នុងទីធ្លា ដែលលំអដោយសួនរុក្ខជាតិ នឹង ដើមបុប្ផានានា ។ សំឡេងអ៊ូអរកើតមានឡើងភ្លាម ។

នុះហ្ន៎! នៅក្រោមម្លប់ស្វាយ, ក្មេងតូចៗ ប្រជុំគ្នាលេងល្បែងកូនឃ្លី ស្រែកហ៊ោកញ្ជ្រៀវខ្ទររំពង ។ ឆ្ងាយពីនេះបន្តិច, សិស្សខ្លះទាត់សី លើកជើង, លើកដៃ, រត់ដេញតាមសី បញ្ចេញស្នៀតយ៉ាងស្វាហាប់ ញើសហូរស្រោកពេញទាំងខ្លួន ។ ចំណែកសិស្សធំៗ បន្តិច, មិនសូវរបល់

ដូចគេទេ បែរជានាំគ្នាឈរប្រជុំនិយាយចំអកចំអន់គ្នាសើចអឹកកង ។ ខ្លះមិនសូវបានរៅហារក៏ឈររហេមចាំស្ដាប់សិស្សចំបងម្នាក់និទានរឿង ដែលគេធ្លាប់ប្រទះឃើញក្នុងសៀវភៅ ។ សិស្សមួយហ្វូងទៀត កំពុងរត់វៃញ្ញាដេញដណ្ដើមកូនបាល់តូចមួយដែលគេបោះចុះ, បោះឡើងពីម្នាក់ទៅម្នាក់ ។

ពេលដែលសិស្សកំពុងតែសប្បាយ សូរជួងបានបន្លឺឡើងហាក់ដាច់មេត្តា បង្ខំឲ្យសិស្សានុសិស្សចូលទៅកាន់ថ្នាក់រៀនវិញ ។

លី- ធាមតេង

ក- ពន្យល់ពាក្យ

វិស្សមោកាស: ឱកាសឈប់សំរាក (la récréation) ។

សួនរុក្ខជាតិ: សួនដាំកូនឈើស្រស់ ។

យ៉ាងស្វាហាប់: យ៉ាងអង់អាច, យ៉ាងខែងរែង ។

និទានរឿង : និយាយរឿង (Raconter d'une histoire) ។

រត់វៃញ : រត់ប្រសាច, រត់រចល់ ។

សិស្សានុសិស្ស : (សិស្ស + អនុសិស្ស) សិស្សជាច្រើន ។

១- អក្ខរាវិរុទ្ធ

សំពក (សរសេរឥតសង្កត់ទេ)

នុ៎ះហ្ន៎ ! (កុំសរសេរ នោះន៎ !)

ហ៊ោ (សរសេរគ្មាន រ ទេ)

ហូរ (ហូរមាន រ ឯហៅឥត រ ទេ)

គ- វាក្យស័ព្ទ

អនុញ្ញាត ន. (សិស្សសុំអនុញ្ញាតពីគ្រូឈប់បីថ្ងៃ)

អនុញ្ញាត គុ. (លិខិតអនុញ្ញាត)

អនុញ្ញាត កិ. (គ្រូអនុញ្ញាតឲ្យសិស្សឈប់បីថ្ងៃ)

បោះ កិ. (បោះបានបោលទៅដី)

បោស កិ. (បាវស្រីបោសសំអាតផ្ទះ)

---

# ៣_វិស្សមកាល

វិស្សមកាល! អ្នកផងគង់ជ្រាបស្រាប់ហើយនូវកំឡាំងនៃសេចក្ដីសប្បាយដែលពង្រីកទ្រូងនៃយុវជនសាលារៀននៅពេលដែលជំពើបលើឈប់ពីរៀន ៗ ក៏កងធំ! ឈប់ពីរៀន! ពាក្យចំឡែកអស្ចារ្យដែលបើកទ្វារជើងមេឃដ៏ទូលាយទៅខាងមុខបាន ៗ បក្សាដែលគេបង្ខាំងនៅក្នុងទ្រុងហើយបើគេបើកទ្វារលែង មានសេចក្ដីត្រេកអរយ៉ាងណាមិញ ក្មេងសិស្សទាំងឡាយ ក៏សប្បាយយ៉ាងនោះដែរ ខ្លួនគេដូចជាស្រាល ចង់សាត់អណ្ដែតទៅតាមអាកាស, កិរិយាគេដូចជាមនុស្សស្រវឹង គឺស្រវឹងនឹងសេរីភាព ឈប់

ពីរខែ ! គេមិនដែលឃើញសប្បាយអ្វីបានយូរម្ល៉េះទេ ៗ គេរួចពីចំណងនៃការរៀនសូត្រ ដែលត្រូវបំពេញពល់ថ្ងៃជាអចិន្ត្រៃយ៍ ៗ ណាហើយសៀវភៅធំៗដ៏មានវិជ្ជាពិបាកឡើងធំធឹតមុខ ! ណាហើយសំឡេងគ្រូអាចារ្យដែលបង្ខិតបង្ខំ, ស្តីបន្ទោស, ណាហើយគ្រែដំណេកដែលមានសង្កើចពាសពេញ ! ណាហើយកន្លែងទទួលភោជនាហារដែលជុំក្លិនផ្អាប ៗ ជាប់ទីងប្រមុះ ! ណាហើយពួកម៉ាកដែលធ្លាប់ស្រឡាញ់គ្នា, ដែលខំប្រកួតប្រណាំងគ្នា . . . ណាហើយ ! ណាហើយ ! គេនឹងទៅជួបជុំឪពុកម្ដាយ, បងប្អូន, ញាតិសន្តាន ៗ គេនឹងបានដេកអស់ពេលតាមចំណង់, បរិភោគតាមឃ្លាន, ដើរលេងតាមកំសាន្ត ៗ ឈប់ពីរខែ, ជាយោ !

ន្ធ- ហាប

ក- ពន្យល់ពាក្យ

វិស្សមកាល : ពេលឈប់រៀនមានរយៈកាល (Vacances) ។

បក្សា : សត្វស្លាប, បក្សី ។

សេរីភាព : ការៈធ្វើអ្វីបានតាមបំណង (liberté) ។

អចិន្ត្រៃយ៍ : ជានិច្ចកាលពេល (ហួសនិស្ស័យ)

ភោជនាហារ : ម្ហូបចំណីជាគ្រឿងបរិភោគ ។

១- អក្ខរាវិរុទ្ធ

វិស្សមកាល (សរសេរ ស ជើង ស)

គ្រេតអរ (មាន រ នៅខាងចុង)

អចិន្ត្រៃយ៍ (សរសេរ យ បដិសេធ)

ក្អូន (សរសេរ ក មិនមែន ខ ទេ)

គ. វាក្យស័ព្ទ

ពីរ គុ. (ខ្ញុំមានកូនពីរនាក់)

ពី កិ. (អ្នកមកពីណាមក)

នៅ កិ. (ផ្ទះខ្ញុំនៅក្នុងក្រុងភ្នំពេញ)

នូវ និ. (ខ្ញុំជូនលោកនូវសព្ទសារធុកាពរ)

---

## ៨_កុំទុំមុនស្រគាល

ផ្លែឈើទាំងពួង ដំបូងលេចចេញមកជាក្តិប, រួចពីក្តិបទៅជាខ្ចី, រួចពីខ្ចីទៅជាចាស់ លុះរួចពីចាស់ទើបទៅជាស្រគាល ផុតពីស្រគាលទើបទៅជាទុំ តាមលំដាប់គ្នាហូរហែ មិនដែលផ្លែឈើណាទុំរួចបានចាស់ រួចបានខ្ចីវិញនោះទេ ៗ

សុភាសិតនេះ ជាពាក្យប្រៀបធៀប ។ បុរាណចារ្យយើង លោកប្រដៅមនុស្សថា កុំឲ្យធ្វើជាចេះដឹងមុនការរៀនសូត្រ ។

កុំឲ្យតាំងខ្លួនធ្វើជាអ្នកមានស្ដុកស្ដម្ភមុនមានទ្រព្យសម្បត្តិ ។

កុំឲ្យតាំងខ្លួនធ្វើជានាម៉ឺនមុនទឹងមានព្រះរាជប្រកាសតាំង ។

បើលើកខ្លួនខុសទំនងដូចពោលមកខាងលើនេះ មុខជានឹងវិនាសដោយហេតុណាមួយមិនខានឡើយ ។

មានន័យមួយទៀតលោកប្រៀបថា កំឡោះក្ដី, ក្រមុំក្ដី, ដែលជនជាអាណាព្យាបាល -មានមាតាបិតាជាដើម, មិនទាន់រៀបចំទុកដាក់ខ្លួនត្រឹមត្រូវឲ្យមានអាពាហ៍-ពិពាហ៍ទេ ហើយស្រាប់តែប្រព្រឹត្តរំលោភគន្លងប្រវេណីនោះ ក៏លោកចាត់ទុកថា "ទុំមុនស្រគាល" ដែរ ។

ប៊ូ–ប៉ូ

ក- ពន្យល់ពាក្យ

សុភាសិត : ពាក្យទំនៀមដ៏ល្អប្រសើរ ។

បុរាណាចារ្យ : បុគ្គលជាគ្រូជាន់ដើម, ជាន់មុន ។

ព្រះរាជប្រកាស : សេចក្ដីផ្សាយចេញពីព្រះរាជា ។

អាណាព្យាបាល : អ្នកទំនុកបំរុង, អ្នកថែរក្សា

ប្រវេណី : ច្បាប់ដាទម្លាប់, ទំនៀមទម្លាប់ ។

ខ– អក្ខរាវិរុទ្ធ

ស្រគាល (សរសេរ គ ស្រៈ អា)

ស្គុកស្គម (សរសេរ ម ជើង ក)

បិតា (អ.ថ. ប៊ីដា សរសេរ បិតា)

គ– ពាក្យស័ព្ទ

ទុំ គុ. (ផ្លែឈើទុំមានរសជាតិផ្អែម)

ទំ កិ. (បក្សីទំលើមែករុក្ខា)

ការ ន. (ការរៀនសូត្រ, គេធ្វើការ)

ការ កិ. (បងទូកការខ្យល់ព្យុះ)

ការ កិ (ស្រីការសូត្រដាក់បំពង់)

កាណិ ន (ព្រះរាជបុត្រីទ្រង់កណ្ដាលនៅព្រះកាណ៌)

ការណ៍ ន.(ហេតុ, ដំណើររឿងការណ៍សុទ្ធជារឿងកំរ)

កា កិ.(ខ្ញុំកាខ្ទង់សំបុត្រផ្ញើទៅប្អូនខ្ញុំ)

កា ន (ខ្ញុំផឹកទឹកអស់មួយកា)

ប្រកាស ន.(ប្រកាសមួយហាមមិនឲ្យលក់ស្រាថ្ងៃសីល)

ប្រកាស កិ.(រាជការប្រកាសឲ្យរាស្ត្រមកបង់ពន្ធ)

នឹង និ.(ខ្ញុំនឹងបងខ្ញុំចូលហ៊ុនគ្នារកស៊ី)

ហ្នឹង វិ.ស.(រឿងហ្នឹងជារឿងបំភ្លេក)

ទឹង គុ ឬ.កិ.វិ.(នាវាធំបើកទៅនឹងថ្កល់)

ទឹង កិ.គុ.(ស្អែកខ្ញុំទឹងទៅលេងជាមួយអ្នក)

ណា សព្វ.(កាលណាបានអ្នកមកជួបខ្ញុំ)

ហ្នា ឬ ណា និ.(កុំខឹងហ្នានាងក្មេ)

## ៩ – ទីក្រុងសៀមរាប

បណ្ដាក្រុងទាំងឡាយ ដែលជាទីរួមខេត្តក្នុងកម្ពុជរដ្ឋ បើនិយាយតាមទីកន្លែងជារមណីយដ្ឋាន ក៏មិនមានក្រុងខេត្តណាយកឈ្នះក្រុងសៀមរាបបាន ពិតមែនតែក្រុងនេះតូចជាងគេ ។

តាមដងស្ទឹង, មានផ្លូវនៅត្រើយទាំងសងខាង ប្រកបដោយព្រឹក្សាជាដំណាំ មានស្លឹកខៀវខ្ចី ត្រជាក់ត្រឈឹងត្រឈៃគួរជាទីកំសាន្ត ។ ទឹកស្ទឹងថ្លាហូរពេញត្រៀបមាត់ច្រាំងហូររមៗ, មានរហាត់ទឹកវិលរគាងឮសូរង៉ើតអែប... តាំងពីខាងលើផ្សាររហូតទៅខាងក្រោមផ្សារគួរឲ្យគយគន់ ។

នៅតាមមាត់ស្ទឹងត្រើយទាំងសងខាង មានវត្តជាច្រើន តែវត្តដែលគួរចូលមើលនោះគឺវត្តព្រហ្មរ័តន៍ ដែលជាវត្តបុរាណជាងគេប្រកបក្បាច់នគរជាន់ថ្លីចំណាន ។

នៅក្សេត្រស្ពានថ្ម មានទឹកទន្លេសម្រាប់ចិញ្ចឹមសត្វ ។ ត្រង់នេះមានមហាសណ្ឋាគារមួយយ៉ាងទាន់សម័យ សំរាប់ទទួលពួកទេសចរ ។

ញ៉ង-ខាត់

ក- ពន្យល់ពាក្យ

ទីរួមខេត្រ : ទីប្រជុំជនរបស់ខេត្រ (Chef - lieu) ។

រមណីយដ្ឋាន : ទីដែលជាសុខមនោរម្យ ។

ព្រឹក្សា : ដើមឈើ, ព្រៃដែលឈើដុះច្រើន ។

មហាសណ្ឋាគារ : ផ្ទះសំណាក់យ៉ាងធំ (grand hotel)

ទេសចរ : អ្នកដើរទស្សនា, អ្នកធ្វើដំណើរ (touriste)

១-អក្ខរាវិរុទ្ធ

ខេត្រ ឬ ខេត្ត (សរសេរបានទាំងពីរបែប)

កម្ពុជរដ្ឋ (កុំសរសេរកម្ពុជៈរដ្ឋ)

សណ្ឋាន (កុំសរសេរ សន្ឋាន)

ហ្វង់ (អ.ថ. វ៉ី តែសរសេរ ហ្វ)

សំពប់, សម្រាប់ (ដាក់បានទាំងពីរបែប)

គ- ពាក្យស័ព្ទ

ត្រៀប គុ. (ទឹកឡើងពេញត្រៀបមាត់ប្រាំង)

ប្រៀប កិ. (កញ្ញានេះល្អ ប្រៀបដូចជាទេពធីតា)

ព្រាប ន. (សត្វព្រាបយំថ្ងូរលើដំបូលវិហារ)

សម័យ ន. (វត្តទំនើប ជាវត្តសម័យថ្មី)

ស្រមៃ កិ. (ខ្ញុំស្រមៃឃើញខ្មោចឪពុកខ្ញុំ)

ស្បមៃ ន. (នាងគបស្បមៃទៅស្វាមីវិញភ្លាម)

ទេសចរ ន.ឬ គុ. (ពួកទេសចរដើរលេងអង្គរ)

ទេសចរណ៍ ន. (ទេសចរណ៍ជាការទាក់ទងរវាងប្រទេស)

ជាន់ កិ ឬ ន. (អង្គរវត្តជាប្រាសាទជាន់ចាស់)

ជន់ កិ. (ទឹកទន្លេជន់លិចភូមិ)

ជន ន. ( ជននីមួយ ៗ ត្រូវបេះអក្សរ )

ជន្ទ ន. ( ព្រះជិនវង្សបានប្រហារជន្ទយក្ស )

---

## ១០– ទេសភាពមាត់បឹង

ទិដ្ឋភាពផ្ទៃបឹង គួរជាទីចំពោះអ្នក ណាដែលបានទៅកំ-សាន្ត នូវសម្រស់ដ៏ល្អឆើតគួរចាប់ចិត្ត ។

គេឃើញមានគុម្ពោតត្រស់ទឹកពាំង លេចត្រួយរហាន់មានទាបមានខ្ពស់ គួរជាទីអាស្រ័យនៃបក្សាបក្សីទាំងឡាយ ។ សព្វសត្វដែលត្រូវត្រាច់រកម្ហូបជាចំណី ហិចហើរប្រៀវប្រែប្រវាត់ទៅមក ។ ខ្លះហក់មុជចុះក្នុងទឹកដូចជាមិនចេះល្ហក់សោះ ។ សេចក្តីពិចរៀបនៃសារិកាកែវ ទីទ្រលីង-ត្រលោងមិនចេះឈប់ឈរ ហាក់ដូចជាមានរឿងអ្វីមួយយ៉ាងវែង ហើយពិរោះប្លែក ៗ ដើមព្រលិត, កញ្ឆែត,

កំពីងពួយ ទឹងត្រកួន អើតតរហេង់ពីក្នុងផ្ទៃបឹង ។ ខ្លះ ឈាតផ្កាប្រឈមបញ្ចេញពណ៌ផ្សេង ៗ រង់ចាំស្តាប់សៀងដំពិពេះនៃសត្វទាំងនោះ ។ ព្រៃយោបក់ហោយ បណ្តាលឲ្យកម្រើកអស់ស្លឹករុក្ខជាតិ ទឹងព្រៃជាតិទាំងចាស់ - ខ្ចី ឲ្យយោលរេច ៗ ប្រៀបដូចជាចាក់ត្តុកដាក់គ្នាពុំចេះនឿយហត់ ។ លេកត្តូច ៗ រមៀលអង្កាញ់ដេញប្រលែងគ្នាត្តូនបុះត្តូនឡើង បញ្ចេញអ្នកប្បកិរិយាឲ្យដឹងថាសប្បាយក្រៃលែង ។ ដូនជាអាកាសស្អាតផេង មានដុំពពកមួយ ៗ រសាត់កៀនលយផង នាំឲ្យខ្លុះឃើញស្រមោលនៅក្នុងទឹកថ្លាល្មេង បីដូចជាមានមេឃមួយទៀតយ៉ាងប្លែក នៅក្នុងព្រៃនោះឯង ។

នេះហើយជាទេសភាពដែលនាំឲ្យយើងចាប់អារម្មណ៍ក្រៃលែង ។

លី - ធាមតេង

ក- ពន្យល់ពាក្យ

ទេសភាព : សភាពឬភាពៈរបស់ស្រុក (Paysage) ។

ទិដ្ឋភាព : ភាពអ្វីដែលគេដាក់ឲ្យឃើញ (Aspect) ។

មច្ឆា : ត្រី, ហ្វូងសត្វត្រី ។

និទានរឿង : និយាយរឿង, ថ្លែងរឿង ។

វារីជាតិ : ពួកដើមឈើតូចៗដុះកណ្ដាលទឹក ។

អតប្បកិរិយា : បុគ្គលពាក្យកេតសម្គាល់បាន ។

ចាប់អារម្មណ៍ : ទាក់ចិត្ត, ដក់ជាប់ក្នុងចិត្ត (Impressionner) ។

១ - អក្ខរាវិរុទ្ធ

គុម្ពោត ( សរសេរ គ ស្រៈ អុ )

គ្រាប់ ( សរសេរគ្រាប់ ឬ គ្រេប )

មុជ ( សរសេរប្រកបទីដ ជ )

ត្នុក ( សរសេរ ត ជើង ល )

មេឃ ( សរសេរ មេ ទីង ឃ )

គ - វាក្យស័ព្ទ

ត្អុក ន.(អ្នកកំប្លែងលោតបាក់ត្អុក)

ថ្អុក ន.(ទឹកភ្លៀងហូរធ្លាក់ក្នុងថ្អុក)

ព្រឹន កិ.ឬ គុ.(ទ្រង់ស្មៀងយល់, ទឹកថ្លាស្មៀង)

ឆ្វេន គុ.(ក្មេងដំបៅកែងដៃឆ្វេង)

---

## ១១ ក្អែកមួយជាក្អែកដប់

មានសេចក្ដីនិទានថា កាលនោះ បុរសម្នាក់ដើរទៅក្នុងព្រៃ ប្រទះនឹងមាសប្រាក់ជាច្រើន រកមើលម្ចាស់ពុំឃើញ ៗ បុរសនោះពុំហ៊ានយកឡើយ ព្រោះខ្លាចបែកការណ៍នឹងមានទោសដល់ខ្លួន ទើបគិតថាចាំអញពិសោធមើលចិត្តប្រពន្ធអញសិន ៗ លុះមកដល់ផ្ទះ បុរសនោះប្រាប់ប្រពន្ធថា "អញចូលទៅបត់ជើងក្នុងព្រៃ ស្រាប់តែសត្វក្អែកមួយ

ហើរចេញពីទ្វារធំអញទៅ ឯងលាក់ឲ្យជិតខ្ជាប់ក្រែងបែកការណ៍កើតនិន្ទាដល់រូបអញ" ។

ឯប្រពន្ធលាក់រឿងនេះមិនបាន ក៏និយាយប្រាប់ស្រីម្នាក់ខ្លួនថា «មានក្អែកពីរចេញពីទ្វារលាមកប្ដីទៅ» ។ ស្រីនោះឯង និយាយប្រាប់គ្នីគ្នាត ៗ ទៅរហូតដល់ក្អែកឡើងដល់ដប់ ។ រឿងនេះជ្រាបដល់ស្ដេច, ព្រះអង្គហៅបុរសប្ដីទៅសួរទ្រង់ជ្រាបថាមិនពិតទេ គឺគ្រាន់តែពិសោធចិត្តប្រពន្ធប៉ុណ្ណោះ តាមពិត ដើមហេតុគឺមាសប្រាក់នៅក្នុងព្រៃ ។ ព្រះអង្គទ្រង់ប្រើឲ្យទៅយកមាសប្រាក់នោះមកចែកបុរសនេះពាក់កណ្ដាល យកដាក់ឃ្លាំងព្រះរាជទ្រព្យពាក់កណ្ដាល ។

ប៊ូ - ប៊ូ

ក- ពន្យល់ពាក្យ

និន្ទា : ពាក្យរិះគន់, កេរ, ហេតុគួរខ្មាស ។

លាមក : កាកអាហារចាស់, អាចម៍ ។

ម្រាក់ : មិត្តជាស្រីដូចគ្នា ។

ព្រះរាជទ្រព្យ : ទ្រព្យសម្បត្តិសំរាប់ព្រះរាជា ។

១– អក្ខរាវិរុទ្ធ

ឈាមក (អ ឋ ឈាមក់ ឥតមានបន្តក់ទេ)

មាស (ឥតមានបន្តក់ទេ)

គ–ពាក្យសព្ទ

ពិសោធ កិ. (ប្ដីពិសោធចិត្តប្រពន្ធ)

ពិសោធន៍ ន. (គេធ្វើពិសោធន៍មើលជាតិឱសថ)

ឈាក់ កិ. (ឈាក់សម្លូយបាន, ជាតិឈាក់ឈើ)

លក្ខណ៍ ន. (ស្រីល្អគ្រប់លក្ខណ៍កម្ររកបាន)

លក្ត័ប្កល័ខ ន. (ស្បង់លោកជ្រលក់ល័ក្តលឿង)

លក្សណ៍ ន. (ព្រះលក្សណ៍លើកទ័ពទៅច្បាំង)

ទ្រព្យ ន. (សម្បត្តិទាំងនេះជាទ្រព្យរបស់ខ្ញុំ)

ត្រាប់ ក. (ក្រាលកន្ទេលទ្រាប់ក្រោមគូថ)

គ្រប់ ន. (សម្លកក្លួរផ្លែគ្រប់)

---

សម្លាប់ខ្ញុំ

## ១២ - ស្រះស្រង់

ស្រះស្រង់មានសណ្ឋានបួនជ្រុងទ្រវែង ប្រកបដោយក្លីក្រាលថ្មជាជណ្ដើរចុះទៅកាន់ទឹក ។ នៅមាត់ស្រះ មានដើមឈើដុះព័ទ្ធជុំវិញ មានម្លប់ត្រជាក់ត្រឈៃ បណ្ដោយប្រាំបីរយម៉ែត្រ ទទឹងប្រហែលបួនរយម៉ែត្រ ។

ទិសខាងលិចជាមាត់កំពង់ គេកសាងជាទីលានខ្ពស់ ប្រកបដោយបង្កាន់ដៃនាគស៊ើនច្រូងច្រាងចុះទៅកងទឹក ។ ពេលព្រះសូរិយាលិចចុះកាន់អស្ដង្គតប្រទេស , បញ្ចេញពន្លឺរន្ទាលប៉ះមកលើទីលាននេះ បើជាយើងឈប់សម្រាកបន្តិចឈរមើលទៅខាងកើតនៅពេលនុះ រឹតរឹតតែល្អមើលណាស់ៗ

នៅកណ្ដាលស្រះមានប្រាសាទតូចមួយ តែឥឡូវនេះវិនាសហើយ មើលទៅឃើញតែដុំថ្មខ្មៅៗ ។ នៅខាងត្បូងជាទីលាន មានសាលាប្រក់ក្បឿងមួយ ជាទីសំចត ឬសម្រាប់បរិភោគអាហារ ។

យ៉ាង - ខាត់

ក- ពន្យល់ពាក្យ

សណ្ឋាន : ទ្រង់ទ្រាយ , រាងរៅ, សភាព ។

នាគសៀន : នាគងើបក្បាល, នាគអើតក្បាល ។

អស្ដង្គតប្រទេស : ទិស ឬ តំបន់ដែលថ្ងៃលិច ។

ទីលាន : ទីវាល, វាលសំរាប់កសាង ឬហ្វឹកហាត់អ្វីមួយៗ

១- អក្ខរាវិរុទ្ធ

សណ្ឋាន (ជើង ឋ មិនមែនជើង ថ ទេ)

ព័ទ្ធ (ប្រយ័ត្នកុំសរសេរ ពាត់ ឬ ព័ត្ធ)

ប៉ះ (សរសេរ ប៉ វិសជ្ជនីយ)

ប្រក់ (សរសេរមានរស្សសញ្ញា)

សម្រាប់ ឬ សំពប់ (ដាក់បានទាំងពីរបែប)

បរិភោគ (សរសេរប្រកបទឹងអក្សរ គ)

គ- ពាក្យស័ព្ទ

ទុំ សព្ទ. (ទុំឯងជាប្រាសាទស្រះស្រង់)

នោះ វិ.ស. (រូបសីហៈទាំងនោះ ងើយមុខស្មើន)

លាន ន. (ពួកបរិវារប្រជុំគ្នានៅក្នុងលាន)

លាន ប.ស. (ឆ្នោតពិសេសរង្វាន់ធំត្រូវបានបីលានរៀល)

---

## ១៣- អ្នកតាដំបងដែក

នៅក្បែរដងផ្លូវ ដែលនៅជាយព្រៃមួយ , មានដើមពោធិធំមួយដើមបែកមែកសាខា ហើយបោលម្លប់ត្រឈឹងត្រឈៃ នៅលើដីទំពែកដែលឥតស្មៅដុះ ។ កាលបើមានខ្យល់បកមកម្ដងៗ ស្លឹកព្រឹក្សនោះបញ្ចេញសូរព្រឺៗ ។

បីដូចជាគេញាក់ញីក្រដាស ។ ឯឫសដែលសំយុងចុះពីមែក ក៏យោលរេរាដូចជាខ្សែដងក្ដោងនាវាមួយដែរ ។

នៅជាប់នឹងគល់ដែលមានផ្នត់ក្ខួញ ៗ នៃស្ដេចឈើនេះ មានកូនខ្ទមមួយនៅជ្រកកំព្រោន ដ៏មានដំបូលធ្វើពីបន្ទះក្ដារ ពុករយើករយោក គ្រាំគ្រាដោយជរាភាព ។ កំទេចថ្មដ៏មាន់, ពា , ថ្មឹដួប, ស្លឹកបេក ដែលមានគ្រាប់បាយក្រៀមក្រពិត នៅជាប់,ក៏មាន់នៅដេរដាសលើក្ដារក្រាលនៃកូនខ្ទម ៗ

ខាងក្នុងកូនរាននេះ ដែលមានងងឹតស្អាប់ ៗ តាំងនៅ, មានបដិមាមួយឆ្លាក់ខ្ញាពីថ្មពណ៌ប្រផេះ មាឌប៉ុនកូនក្មេង អាយុប្រាំឆ្នាំ ពានាកនៃស្រ្តីពណ៌លោហិត ដៃកាន់ដំបងមួយយ៉ាងធំ ហើយធ្វើមុខក្រញីវក្រញូវ មាត់ពេបស្បែបទៅរកវាលស្រែ ដែលនៅចំពីមុខខ្លួន ៗ រូបនេះហើយ ជាតួ

អកតាដំបន់ដែក ដែលមានបុទ្ធិបេស្តា ធ្វើឲ្យអ្នកភូមិជិតខាងខ្លាចញាប់ញ័រគ្រប់ៗគ្នា ។

ខ្វ - ឃាប

ក— ពន្យល់ពាក្យ

ជីទំពែក : ដីវាលគ្មានស្មៅដុះ ។

ស្ដេចឈើ : ឈើយ៉ាងធំ, ដើមឈើធំលើសលែង ។

ជរាភាព : សភាពចាស់ទ្រុឌទ្រោម ។

ងងឹតស្អាប់តាំងនៅ : នៅក្នុងងងឹតឥតឃើញពន្លឺច្បាស់ៗ

ពានាគនៃទ្រង់ : បង់គកនៃទ្រង់ពាក់ឈៀងទៅម្ខាង ។

បុទ្ធិបេស្តា : បុទ្ធិអំណាច, បុណ្យបារមី ។

១- អក្ខរាវិរុទ្ធ

អួរ ( មានរ នៅចុង )

ដុះ ( សរសេរ ដ ស្រៈ អុ វិសជ្ជនីយ )

ក្រដាស (ឥតមានសេស្រសញ្ញាពីលើទេ)

ក្ដារ (សរសេរមាន រ នៅចុង)

ញ៉ែរ (សំយោគសញ្ញាត្រូវដាក់លើ ញ)

គ- វាក្យស័ព្ទ

ដុះ កិ. (ដើមឈើដុះនៅក្នុងព្រៃជាច្រើន)

ដុស កិ. (ដាងដុសខាត់តុទូឡូរលោង)

ព្រឹក្សា ន. (បក្សីទំលើមែកព្រឹក្សា)

ប្រឹក្សា កិ. (ពូសុខពូសៅប្រឹក្សាការជាមួយគ្នា)

ពានា កិ. (ខបាសិកាពានាសំពត់ស)

ពណ៌នា កិ. (ខ្ញុំសូមពណ៌នាពីរឿងទេវ័ន្ត)

---

## ១៤- ភូមិទួលក៏

តាមដងផ្លូវទៅកំពត ចំងាយដប់ប្រាំគីឡូម៉ែត្រពីភ្នំពេញ មានភូមិមួយដ៏មានផ្ទះជាប់ៗ ពីគ្នា ខ្លះសង់ក្រោមដើមត្នោត

ខ្ទះក្រោមឫស្សី ខ្ទះព័ទ្ធជុំវិញដោយដើមចេក ។ ភូមិនេះឯងមាននាមប្រាកដសព្វថ្ងៃនេះ ថាភូមិ "ទួលគី" ប៉ុន្តែគង់បុរាណកាល ភូមិទួលគីបានសន្មតហៅថាភូមិ "ទល់គ្រៃ" ទេ ។ ព្រោះរឿងព្រេងប្រចាំស្រុកបានដំណាល (raconter) ថា នៅកន្លែងនោះ ព្រះមហាក្សត្រសម័យបុរាណវែងឆ្ងាយមួយព្រះអង្គ ទ្រង់បានបែកគ្រៃដល់សេនាឯកព្រះអង្គមួយ រូបដល់ត្រឹមនោះ ។

សងខាងផ្លូវរទេះមួយ គេឃើញដុះដើមសង្កែ ដើមពោធិ៍ ដើមត្នោតក៏មានដែរ ។ ផ្លូវរទេះនេះឯង មើលទៅ ដូចជាល្អូនដំរង់ (droit) ទៅផ្ទះពីរ-បីនៅឯនាយ ប៉ុន្តែមិនយ៉ាងនេះទេ វាទៅជាក្រវេចក្រវៀនហួសពីនោះទៅទៀត រួចបែកជាពីរ មួយទៅឯព្រៃត្នោតឯនាយឆ្ងាយនោះដែលលេចនៅជាចន្លោះដំបូលស្លឹកបបួននៃផ្ទះអ្នកស្រុក , មួយទៅកំបាំងបាត់ទីងព្រៃពោធិ៍លាយឡំនឹងក្រោងឯទៀតច្រើន ។

ក- ពន្យល់ពាក្យ

រឿងព្រេង : រឿងនិទានតៗគ្នាមកជាអង្វែងហើយ ។

បុរាណកាល : ពេល, វេលាពីយូរមកហើយ ។

សេនាឯក : សេនាចំបង, សេនាជំនិត, នាម៉ឺនធំ ។

ខ- អក្ខរាវិរុទ្ធ

ចំណាយ ឬ ចណ្ណាយ (ដាក់បានទាំងពីរយ៉ាង)

ត្នោត (សរសេរ ត ជើង ន មិនមែន ថ ទេ)

សន្ទូច (ឥតមានស្រៈសញ្ញាទេ)

លាយឡំ (កុំសរសេរ លាយលំ)

រុក្ខា (កុំសរសេរ រុក្ខា)

គ- ពាក្យស័ព្ទ

ឫស្សី (គេកាប់ឫស្សីយកមកធ្វើរនាបផ្ទះ)

ឫសី ន. (ឫសីមួយអង្គចំរើនធម៌ក្នុងព្រៃភ្នំ)

ព្រេង ន. (សេចក្ដីដំណាលមានមកពីព្រេង)

ប្រេង ន. (បន្លៀងតូចនេះដាក់ប្រេងបានច្រើន)

---

## ១៥ - ព្រះក្សត្រីផ្ដិសស្កល់

ខ្ញុំបានស្គាល់ព្រះក្សត្រីមួយអង្គដែលផ្ដិតសារិបកល់ ៗ ឆ្នាំ ក្រោយដែលគម្ពុនរដូវតន្តឹមហួសទៅ ។

ព្រះនាងមិនមែនផ្ដិតហួតដល់រាប់រយឆ្នាំនោះទេ, គឺគង់រង់ប៉ុនានខែប៉ុណ្ណោះ តែយើងនាំគ្នាផ្សាយហាក់ដូចជាមួយសតវត្ស ។ នៅគ្រាដែលព្រះនាងផ្ដិតស្កល់ គេមិនសួរព្រួសសៅម្រេកបត្បាបក្សិស្រែកទៀតទេ ឯស្លឹកឈើ, ផ្កាឈើក៏មិនមានល្អគលាស់ទៀយ ។ គេឃើញតែមេឃក្រោសមម្រជាំស្ងាំងនៅក្រោមផ្ទៃមេឃប្រផេះប៉ុណ្ណោះ ។ ដូនកាលមានអព្ភាគគ្រប់ងឹតផ្ទៃពសុធា, ដែលបណ្ដាលឲ្យធម្មជាតិស្ងប់ស្ងាត់ត្រឈឹងបីដូចជាទីរហោស្ថានផង ។

មិនយូរប៉ុន្មាន មានក្សត្រាមួយអង្គប្រដាប់ព្រះកាយដោយពណ៌ខៀវបំព្រង បានយាងមកដាស់ព្រះនាងឲ្យតើនឡើង ដោយទ្រង់ចាប់ទាញព្រះហស្ថដ៏ទន់ក្ងន់នៃព្រះនាងដែលកំពុងតែផ្ទំស្កប់ស្កល់ ។ គ្រានោះឯង ព្រះអាទិត្យក៏ចាំងបែនរស្មី, មហាមេឃឡើងពណ៌ខៀវស្រងាត់ ត្រួយរុក្ខជាតិក៏លូតលាស់ខ្ចីល្អក់, បុប្ផផ្ការីកស្រស់ស្អាយ បំណែកបក្សាបក្សីក៏ស្រែកកញ្ជ្រៀវគឹកកងរំពងឆ្លើយឆ្លងគ្នា ។

ព្រះក្សត្រីនេះឯងគឺហិមន្តរដូវ ដែលមានព្រះក្សត្រាជាវសន្តរដូវមកទទួលភារៈបន្តពីព្រះនាងទៅទៀត ។

លី - ធាមតេង

## ក - ពន្យល់ពាក្យ

ហិមន្តរដូវ : រដូវរំហើយ, រដូវរងា, រដូវត្រជាក់ ។

រហោស្ថាន : ទីស្ងាត់ដែលគ្មានមនុស្សនៅ (Désert) ។

តេីន : ក្រោក, ក្លាក់, តើប (ពាក្យសព្ទ) ៗ

ព្រះហស្ត : ដៃ (ពាក្យសព្ទ) ៗ

១- អក្ខរាវិរុទ្ធ

គម្ពុនាជូរ (សរសេរនៅដើមគេ)

ផ្ញុំ (កុំសរសេរ ផ្ញុំ)

សម្បុរ (សរសេរផ្សេងៗតែអានជាសំបុល)

ជូនប្អូន (ដាក់បានទាំងពីរយ៉ាង)

ពស្មជា (កុំសរសេរ កស្មុជា)

ទ្រព្យ (កុំសរសេរ ទ្រព្យ)

គ- ពាក្យសព្ទ

ដាស់ កិ. (ម្ដាយដាស់កូនឲ្យក្រោកឡើង)

ដាស កិ.វិ (ស្មៅដុះដាសពេញដី)

ដាស កិ. ( គេដាសស្ករឲ្យគឹងល្អ )

## ១៦- វិធីបញ្ចាន់អារក្ស

នៅពីមុខពនម៉ាដែលសង់ជាច្រើនថ្នាក់ ហើយដែលរៀបតុបតែងដោយស្លាធម៌ បាយសី ទឹងមានឆ័ត្រមួយគ្របពីលើ, ក្មេងមួយវង់ប្រគំរង្វើល ៗ តាមចង្វាក់ស្គរស្គរស៊ោ ៗ គ្នា ៗ សំឡេងពុំអញ្ជូគ្រលួចបណ្ដើរទំនុករបស់អ្នកច្រៀងយ៉ាងលន្លង់លន្លាចដែលគេហៅថាបទអន្លង់ខ្លាច ៗ

យាយចាស់ម្នាក់ពានាសំពត់ជាតិអង្គុយញាក់ដើងម្ដង ៗ ជួនស្ងាប, ជួនបើកភ្នែកធំ ៗ រួចស្រាប់តែគ្រវីញនខ្លួនពីរ-បីដង ក៏លើកដៃឡើងរាំតាមចង្វាក់ភ្លេង ៗ គាត់ក្រោកឡើងរាំរែកចាក់ក្បាច់បំទើតបំទយប្រទក្សិណពនម៉ា ដែលភ្លឺព្រោងព្រាតដោយពន្លឺភ្លើងទៀនទឹងធូបដ៏មានផ្សែងហុយទ្រលោម ៗ គាត់រាំចាក់ក្បាច់ការនៃតែញាប់ឡើង ៗ, ឯពួកក្មេងក៏ខំសំពះស្គរឥតប្រណីដៃ ដើម្បីបំពេញចិត្តមេកន្ទោងខ្ញៀវ ៗ រាំអស់ចិត្តគាត់អង្គុយចាប់តោកគ្រវី រួចសួរកេអកដែលបញ្ចាន់អញ្ជើញ

អស់លោកតើមានការអ្វី? សូមពីរនាក់អង្គុយបត់ជើងខែម និយាយអង្វរករសុំឲ្យជួយសង្គ្រោះដល់ពន្ធ័ចាប ឲ្យមានព្រលឹង សម្បុរ ជាសះស្បើយឡើងវិញ ។

រូបសព្វគ្រប់ហើយ រូបមេមត់លើកដៃសំពះ រូបទទះ កន្ទុលផាំង ស្រាប់តែខ្មោចចេញបាត់ទៅ នៅសល់តែរូប ដូនចាស់ដូចធម្មតា ។

លី-ធាមតេង

ក-ពន្យល់ពាក្យ

ពនមា : ពនដែលសង់ដម្កល់គ្រឿងសក្ការៈ ។

អន្ទង់ខ្មោច : លួងលោមខ្មោច, ណៃនាំខ្មោច ។

ជាតី : ក្រណាត់ក្រហមជ្រលក់ស្រាប់, ក្រណាត់ពណ៌ឈាម ។

សំពង់ស្គរតតប្រណីដៃ : វាយស្គរយ៉ាងញាប់ដៃ ។

កន្ទោងខៀវ : ឈ្មោះខ្មោចអារក្សមួយយ៉ាងសាហាវ ។

គោក : ជើងពានរបស់អារក្ស ។

អស់លោក : ពាក្យសំរាប់ហៅបញ្ចើចខ្មោចអារក្ស ៗ

ស្នំ : ស្ត្រីអ្នកបំរើអារក្ស ៗ

ពងីបាប : ពាក្យអារក្សហៅអ្នកជម្ងឺ ៗ

១- អក្ខរាវិរុទ្ធ

ពន (កុំប្រឡំនឹង រៀន)

ស្គរ (សរសេរមាន រ នៅចុង)

ប៊ុគ (ឥតមាន រ នៅចុងទេ)

គ្រលួប (សរសេរ គ្រ)

គ្រញែង (សរសេរ គ្រ)

សម្បុរ (មាន រ នៅខាងចុង)

គ–ពាក្យសព្ទ

វង់ ន. (ភ្លេងមួយវង់កំពុងប្រគំ)

វង់ ន. (កញ្ច្រែងមានវង់មូលក្រឡង់)

វង្ស ន. (ឯងជាវង្សត្រកូលអ្នកណា)

# ១៧- ស្ទូចត្រីនៅមាត់ស្ទឹងសែន

គូកនពីរនាក់ គឹមនឹងសាន រៀននៅសាលាជាមួយគ្នា ឆ្លៀតឱកាសថ្ងៃព្រហស្បតិ៍ ក៏ដើរទៅស្ទូចត្រីនៅមាត់ស្ទឹងសែន ។ លុះព្រឹកឡើងវានាំគ្នាចេញទៅពីព្រលឹម ដ៏មានសំលៀកបំពាក់ចាស់ៗ មួកធំសម្រាប់ដើម្បីថ្កាំងចំហាយព្រះអាទិត្យផង ។ ចៅគឹមលីដងសន្ទូចមួយ ដ៏មានខ្សែ, ផ្លែសន្ទូច, កំសួលនិងប្រអប់ដាក់នុយ ។ ចៅសានកាន់ល្អីស្បៀងអាហារ ។ ក្មេងទាំងពីរទៅឈប់នៅកន្លែងមួយ នាមាត់ទឹកដ៏មានម្លប់ល្អ ។ វាស្ទូចនៅទីនុះ ។ ដំបូងគ្មានត្រីមកស៊ីសោះ គឹមនឹងសានពុំហ៊ានកំរើកខ្លួនឡើយ ក្រែងត្រីផ្អើល ។ មួយស្របក់ មានត្រីច្រើនហែបហែលនាំខ្ទង់ទឹក ។ កំសួលសន្ទូចកញ្ឆោលឡើងម្ដងៗ គឺត្រីស៊ីសន្ទូច វាវាត់ដងសន្ទូចឡើងបានត្រីមួយៗ មិនយូរប៉ុន្មានវាបានត្រីពេញត្រក

វាសប្បាយចិត្តនឹងនាំគ្នាត្រឡប់ទៅផ្ទះវិញ ។ ម្ដាយវាទាំងពីរនាក់ ក៏មានសេចក្ដីរីករាយ ហើយយកត្រីធ្វើម្ហូបសំរាប់ពេលបាយថ្ងៃត្រង់ ។

ពូរ-អ៊ុម

ក- ពន្យល់ពាក្យ

គូកន : មិត្តសំឡាញ់, គៀនបន, មិត្តភក្តិ ។

ស្ទឹងសែន : ឈ្មោះស្ទឹងមួយហូរកាត់ភូមិកំពង់ធំ ។

កំសួល : ប្រដាប់បណ្ដែតយោងផ្ទៃសន្ទូច ។

ទុយ : ចំណីដែលសំរាប់បិតផ្ទៃសន្ទូចបញ្ឆោតត្រី ។

ខ្នងទឹក : ផ្ទៃទឹក ។

ខ-អក្ខរាវិរុទ្ធ

ធ្លៀត (សរសេរ ធ ជើង ល មិនមែនឈទេ)

ព្រលឹម (ប្រយ័ត្ន កុំសរសេរ ប្រលឹម)

ប្រអប់ (មិនមែនដូចពាក្យហៅថា ផ្អប់ ទេ)

គ. ពាក្យស័ព្ទ

គូ ន.(គូស្វាមីភរិយា, ឆ្នាមួយគូ)

គូរ កិ.(ផាងគូររូបទេសភាពយ៉ាងល្អ)

នាក់ ន.(មនុស្សបីនាក់មកដល់ផ្ទះខ្ញុំ)

អ្នក ន.(អ្នកណាខ្លះចង់ទៅផ្សារ)

វ៉ាត់ កិ.(ពៅសានវ៉ាត់សន្ទូចឲ្យជាប់ត្រី)

វត្ត ន.(ព្រះសង្ឃគង់នៅក្នុងវត្ត)

វត្ត ន.(កូនត្រូវធ្វើវត្តប្រណិបតន៍ឪពុក-ម្ដាយ)

វត្ស ឬ វត្សរ៍ ន.(មួយសតវត្សមាន១០០ឆ្នាំ)

វ័ធ កិ.(ក្របីវ័ធកូនក្មេងទាល់តែធ្លាយពោះ)

វឌ្ឍន៍ ន.(ស្រុកទេសចំរើនវឌ្ឍន៍ឡើងហើយ)

វដ្ត ន.(មនុស្សកើតស្លាប់ក្នុងវដ្តសង្សារ)

ភ៌ ន.(ភ៌មានសេចក្ដីរីករាយ)

ភ កិ.(គេកបង្កើតឲ្យមានល្បែងស៊ី-សង)

ក ន. (ផ្នែកពាក់ប្រឡៅនោក)

ករ ន. (លើកករប្រណម្យដាក់លើសិរសី)

---

## ១៧ _ សត្វរៃនឹងស្រមោច

រៃជាសត្វខ្ជិល ដល់ហេមន្តរដូវកាលណា ក៏ហើរច្រៀងលេងតាមអំពើចិត្តខ្លួន ពុំគិតខ្វល់ខ្វាយនឹងរកស្បៀងអាហារទុកដាក់សំរាប់ខ្លួនឡើយ ។ មានសត្វស្រមោចមួយជាសត្វឧស្សាហ៍ពាំនាំស្រូវអង្ករដាក់ក្នុងសំបុកខ្លួន គិតក្រែងក្តីក្រទៅមុខ ។

លុះដល់ក្បៀនឧរដោតជាំមក ។ សត្វរៃនោះរកអាហារបរិភោគគ្មាន កើតក្តីឃ្លានបំណាំក្រេតពេក ទើបហើរទៅខ្ចីអង្ករស្រមោច ។ ឯស្រមោចកាលបានឮរៃត្រូវដីអង្វរសូមខ្ចីស្បៀងដូច្នោះ ក៏សួរទៅថា ៖ អើរៃ ! កាលអំពីដើមឆ្នាំ

ខែប្រាំងរាំងរះនោះ តើហេតុម្ដេចក៏អ្នកឯងមិនស្វែងរកអាហារទុកសម្រាប់ខ្លួន ។ រៃតបថា៖ សំឡាញ់អើយ ! យើងនេះពុំមានកិច្ចការអ្វីទេ រវល់តែហើរទុំលើឈើព្រៃស្រែកច្រៀងលេងតាមអំពើចិត្តប៉ុណ្ណោះ ។ ស្រមោចឆ្លើយថា៖ អើ ! បើពីដើមអ្នកឯងធ្លាប់ច្រៀងលេងយ៉ាងណា ឥឡូវនេះចូរអ្នករាំទន្ទឹមច្រៀងលេងទៀតទៅ ខ្ញុំឯងនឹងស្ដាប់ផង ។

ឯរៃឮស្រមោចពោលចំអកដូច្នោះ ក៏ខ្មាស់ប្រាជ្ញា ទើបហើរចេញពីទីនោះឆ្ពោះទៅកាន់លំនៅអាត្មា បានក្ដីវេទនាដោយអត់អាហារស្រេកឃ្លាន តាមនិស្ស័យខ្លួនទៅ ។

គិន្ទ (សុគន្ធប្រីជា)

ក- ពន្យល់ពាក្យ

ហេមន្តរដូវ : រដូវប្រាំងមានទឹកសន្សើមច្រើន ។

ខុរ : បង្អុរ, ភ្លៀងធ្លាក់ ។

ខុរជោគជាំ : ធ្លាក់ជាច្រើនសើមជោគដី ។

កំនិរះ : កំនិរនិស្ងួតឥតមានទឹកដក់ ៗ

តាមនិស្ស័យខ្លួន : តាមផលបុណ្យរបស់ខ្លួន ៗ

ខ- អក្ខរាវិរុទ្ធ

អាហារ (មាន រ ឯពិសាគ្មាន រ ទេ)

ហើរ (មាន រ នៅចុង)

ប្រៀន (សរសេរ ប មិនមែន ផ ទេ)

និស្ស័យ (ប្រយ័ត្នកុំសរសេរ និសៃយ)

គ- ពាក្យស័ព្ទ

ហេមន្ដរដូវ ឬ ហិមន្ដរដូវ ន. (រដូវប្រាំង)

សត្វ ន. (មនុស្សសត្វសឹងកើតក្នុងលោកដូចគ្នា)

សាត់ កិ. (ឈើសាត់មកតាមទឹកជំនន់)

សត្យ គុ. (មនុស្សសច្ចៈត្រូវកាន់ពាក្យសត្យ)

សត ន. (មួយសតវត្សមានមួយរយឆ្នាំ)

សត្ត គុ. (សត្តបរិតឈ្មោះធម៌មាន ៧ មេ)

រះ ប. (ថៃ្ងព្រាំងរាំងរះ)

ឫស ន. (កាប់ឫស្សីដោយទាំងឫស)

និស្ស័យ ន. (ព្រះពុទ្ធមាននិស្ស័យជាអ្នកប្រាជ្ញ)

វិស័យ គុ. (កូននេះដូចឪពុកវាសុទ្ធវិស័យ)

---

## ១៩ – វត្តមួយនៅស្រុកស្រែ

មានថ្ងៃមួយ, កាលខ្ញុំធ្វើការឯខេត្តសៀមរាប, មុខងារខ្ញុំបានចាត់ខ្ញុំឲ្យធ្វើដំណើរទៅកាន់ឃុំខ្នារ ដែលជាភូមិមួយនៅដាច់ឆ្ងាយពីទីប្រជុំជនកំពង់ក្តី ត្រាប់ទៅកាន់បានតែផ្លូវរទេះ ទីនិផ្លូវដើរ កាត់ព្រៃដុះដែលសម្បូណ៌ទៅដោយខ្លា, ដំរី, ទន្សោង ក្របីព្រៃ ទីនិសត្វដទៃៗ

នៅជាយភូមិនេះ មានកូនវត្តមួយ ដែលទាញចក្ខុវិញ្ញាណយើងពុំដែលដាច់ ព្រោះជាទីឋានមួយដែលមានទឹកមុខញញឹមស្រស់ អាចធ្វើឲ្យសេចក្ដីអផ្សុកនឿយហត់ទាំងប៉ុន្មានរសាយទៅបាន ។ ប្រូបខឿនខាងមុខវត្ត មានដើមដូងដុះជាជួរស្មើគ្នា យោលធាងចុះឡើងទៅបោសអង្កែលដំបូលកុដិស្បូវតូច ៗ ដែលជ្រកនៅខាងក្រោម មានសណ្ឋានដូចជាមាតាអង្កែលថ្នាក់ថ្នមបុត្រ ។

នៅផ្ទៃផែនដី ដែលបោសស្អាតរលីងរលំ ហើយដែលលំអទៅដោយពណ៌បៃតងនៃស្មៅកាត់តម្រែ មានកូនមាគ៌ាតូច ៗ ដែលគេសំអាតមិនឲ្យមានស្មៅ សម្រាប់ជាគមនាគមន៍ទៅកុដិ, សាលា, ព្រះវិហារដែលមិនមានដំកើងបុកអ៊ុឡើយ ដោយធ្វើសុទ្ធតែពីឈើនិងស្បូវប៉ុណ្ណោះ ប៉ុន្តែសុទ្ធតែជារបស់ស្អាតមានសុរិលទាំងអស់ ។

ឌូ-ហាច

ក- ពន្យល់ពាក្យ

ត្រាច់ទៅកាន់: ធ្វើដំណើរទៅកាន់ ។

ព្រៃដុង. ព្រៃស្ដុក, ព្រៃដ៏គ្រោស់ ។

ម្រឹគា: សត្វជើងបួនដែលរស់នៅដោយព្រៃ ។

ចក្ខុវិញ្ញាណ: វិញ្ញាណដឹងដោយមើលឃើញ ។

គមនាគមន៍: ការដើរទៅ-ដើរមក ។

មាគ៌ា ឬ មគ្គា: ផ្លូវដើរ (Voie) ។

មានស្ពុំលៈ មានរូបពង, មានអង្គកាយ (ឥតមន្ទិល) ។

ខ- អក្ខរាវិរុទ្ធ

ផ្ការ (មុខផ្ការ, ផ្ការសក្ដិ មាន រ នៅចុង)

ត្រាច់ (សរសេរ ត្រេច ក៏បាន)

កុដិ (សរសេរ កុ ប្រកបនឹង ដ ស្រៈ អិ)

ហ្វូង (សរសេរ ហ ដាក់ជើង វ)

គ- ពាក្យស័ព្ទ

ផ្ការ ន. (លោកគង់មានផ្ការជាម៉ឺនភក្តិ)

ផ្ដា កិ. (ងាអាវុធកាប់សត្រូវ)

ផ្ការ ន. (ផ្លូវបានដីមួយផ្ការ)

ឫក ន. (ស្រីនេះមានឫកពាសួតបូត)

ឫក្ស ន. (ថ្ងៃនេះមានឫក្សពារដោតជ័យល្អ)

ព្រោស កិ. (ក្មេងស្រីហែសសម្រាម)

ព្រោះ ន. (ពោះបានបោលទៅដី)

## ២០ - ពេលវេលាជាទ្រព្យវិសេស

មនុស្សដែលច្រើនតែនិយាយថា ខ្ញុំមានពេលតិចពេក មិនអាចរៀនអ្វីៗបានទេ វេលតែធ្វើការងារចិញ្ចឹមជីវិត

គិតគូរដូច្នេះមិនត្រូវទំនងសោះ ព្រោះមនុស្សកើតមកក្នុងលោកនេះ គ្មាននរណាធ្វើការតាំងពីពេលក្រោកពីដេករហូតដល់ពេលដេកវិញទេ ។ មនុស្សគ្រប់រូបតែងមានពេលដេក, ដើរ, ឈរ, អង្គុយ, ធ្វើការ, សំរាក, បរិភោគជានិច្ច ។

ដូច្នេះ ត្រូវយើងគិតថា ពេលទំនេរជាឱកាសសំខាន់បំផុតសំរាប់សេចក្ដីចំរើនរបស់ជីវិតយើង ។ មានអ្នកធ្លាប់គិតលេខមើលឃើញថា: ការអានសៀវភៅល្អ ៗ ត្រឹមមួយថ្ងៃដប់ប្រាំនាទី, ក្នុងរយៈវេលាបួនឆ្នាំកន្លងទៅ នឹងទៅជាអ្នកមានការសិក្សាល្មមយបាន គំនិតគិតគូរក៏ដុះអណ្ដែតខ្ពស់ឡើងច្រើន ។ ព្រោះការបណ្ដុះវិជ្ជាផ្សេង ៗ ដែលខ្លួនស្ម័គ្រចិត្តបង់រៀនសូត្រ ឲ្យបានលូតលាស់ចំរើនពេញលេញល្អ មិនមែនជាប្រយោជន៍ផ្ទាល់ខ្លួនតែម្យ៉ាងទេ គឺជាបច្ច័យឲ្យប្រទេសជាតិចំរើនឡើងទៀតផង ។

ញ៉ុក-ថែម

ក- ពន្យល់ពាក្យ

ទ្រព្យវិសេស : សម្បត្តិដ៏បំណាន, ដ៏មានដម្លៃ ។

នាទី : (ទីនេះ) កម្រិតពេលតូចជាងម៉ោង ៦០ ដង (Minute)

រយៈវេលា : រយៈពេល, កំណត់ពេល ។

បច្ច័យ : ហេតុផលដឹកនាំឲ្យបានដល់អ្វីមួយ ។

ប្រទេសជាតិ : ប្រទេសរបស់ខ្លួន ប្រទេសកំណើត ។

១- អក្ខរាវិរុទ្ធ

បញ្ចឹម (សរសេរ ញ ជើង ច ស្រៈ អឹ)

ទំនេរ (មាន រ នៅខាងចុងបំផុត)

សំពក (ឥតមានរស្សសញ្ញាទេ)

សំពប់ (មានរស្សសញ្ញាលើ ប)

រយៈវេលា (ត្រូវមានយុគលពិន្ទុពីមុខ យ)

ស័ង្គ្រ (សរសេរមានសំយោគសញ្ញាប្រកបនឹង គ្រ)

ម្យ៉ាង (ត្រូវមានមួសិកទន្លេលើជើង យ)

បច្ច័យ (សរសេរ ច ជើង ច សំយោគសញ្ញា)

គ- ភិក្សស័ព្ទ

អាន កិ· (មើលសៀវភៅហៅថាអានសៀវភៅ)

អាន ន. (គេបងអានឲ្យសេះរួចទើបលោតឡើង)

ចិត្ត ន. (ត្រូវមានចិត្តស្នេហ៍នឹងប្រទេសជាតិ)

ចិត កិ. (ចិតត្រសក់មកជ្រលក់ទឹកគ្រឿង)

សូត្រ កិ. (លោកសង្ឃសូត្រធម៌)

សូត្រ ន. (គេចិញ្ចឹមនាងធ្វើសូត្រ)

សូត្រឬ សូត្ត ន. (ធម្មកថិកសម្តែងធម៌ពីព្រះសូត្រ)

---

## ២១ – កំពង់ចាម

កំពង់ចាម ជាអាណាខេត្តចំបងនៃប្រទេសកម្ពុជា ខាង

ការចំរើនផលានុផល ។

ទីប្រជុំជន ឬ ទីរួមខេត្តកំពង់ចាម តាំងនៅជាប់នឹងមាត់ទន្លេមេគង្គត្រើយខាងលិច ដ៏មានមនុស្សកុះកុស្កុតនៅជាច្រើនជាតិ ច្រើនសាសន៍ ។ វិថីខ្វាត់ខ្វែងកាត់ទីប្រជុំជនសំពប់បង្ហាញទេសបទទាំងឡាយ ឲ្យឃើញច្បាស់នូវចលនារបស់ប្រជាជនក្នុងគណាខេត្ត ។ របៀបរៀបចំក្រុងនេះមានសណ្ឋានប្លែកផ្សេងជាងក្រុងដទៃ ហាក់ដូចជាអ្នករៀបចំបន្ទុកស្នាដៃចំឡែកឲ្យផ្សេងពីគេ ។ ផ្លូវទាំងឡាយមិនមែនបែងជាក្រឡាចត្រង្គស្មើគ្នាទេ គឺមានញែក-រង្វេលតាមក្បាច់រចនាដែលបែងចែកពីដើមផ្លូវតែមួយ បីដូចជាផ្កាដែលគេឈាតត្រដាង ។ ក្នុងផ្សារ, មានជនលក់ផលានុផល ដែលកើតក្នុងស្រុកគ្រប់បែបច្រើនយ៉ាងពុំមានខ្វះ ។

ក្រៅពីការចំរើនផលានុផល កំពង់ចាមជាខេត្តមួយចំរើនខាងវប្បធម៌លើសលែងខេត្តនានាក្នុងក្របខ័ណ្ឌនេះ ។ ឯការវប្បធម៌របស់ប្រជាជនក៏កាន់តែមានវឌ្ឍនាការលើសកាល

ពីដប់ឆ្នាំមុនសន្ធឹកណាស់ ។ វិទ្យាល័យមួយដែលសួយ ជាប់ព្រះបរមនាមនៃព្រះបិតាឯករាជ្យខ្មែរ ជាមជ្ឈដ្ឋានផ្សាយ នូវវប្បធម៌ដ៏ត្រឹមស្អាតដល់យុវជនខ្មែរក្តនេះ ។

លី-ណាមតេង

ក-ពន្យល់ពាក្យ

ផលានុផល : ផលផ្សេងៗ, ផលសព្វសារពើ ។

ចលនា : ការរស់រវើក, ការកំរើកជានិច្ច(mouvement) ។

ក្រឡាចតុរង្គ : ក្រឡាបួនជ្រុង, ក្រឡាមានជ្រុងបួន ។

វប្បធម៌ : ការចំរើនខាងប្រាជ្ញា, ការបណ្តុះក្បួនច្បាប់(culture)

អារ្យធម៌ : ការចំរើន, សេចក្ដីចំរើនថ្កុំថ្កើង(Civilisation) ។

វិវឌ្ឍនាការ : ការចំរើនឡើង (Progession) ។

វិទ្យាល័យ : សាលារៀនថ្នាក់មធ្យមសិក្សា(Lycée) ។

ព្រះបិតាឯករាជ្យ : គឺជាអគ្គសម្ដេចព្រះឧបយុវរាជ ន.សីហនុ ។

មជ្ឈដ្ឋាន : ទីជាកណ្ដាល, កន្លែងកណ្ដាល ។

១- អក្ខរាវិរុទ្ធ

កុះកុំ (កុំសរសេរ កុសកុំ ឬ កុះកំ)

នានា (កុំសរសេរ នា ៗ)

សន្ទឹក (សរសេរ ជើងទ ស្រៈ អឹ)

ខេត្ត ឬ ខេត្រ (សរសេរបានទាំងពីរបែប)

គ- ភាក្យស័ព្ទ

កំពង់ ន. (គេចុះទៅកំពង់ដងទឹក)

កំពុង កិ. (គេកំពុងធ្វើការ)

ភជ្ស ន. (ព្រះវ័នសំរាប់ភជ្ស)

ភជៈ ន. (ស្តេបហោងបេញពីភជភិង)

ផ្សារ ន, (ស្ត្រីម្នាក់ទៅផ្សារទិញត្រី)

ផ្សារ កិ. (ជាងផ្សារប៉ោតឲ្យជិត)

ផ្សា គុ (ដំបៅនេះឈឺផ្សាណាស់)

## ២២ - វិបត្តិវប្បធម៌ខ្មែរ

កុនគ្រានាយកលើស្រុកខ្មែរ សៀមប្រមូលយកទៅបំពេនស្រុកសៀមអស់ទាំងគម្ពីរក្បួនខាត នានា ទីងចំណេះវិជ្ជាផ្សេង ៗ ៗ ជាន់នោះ ដោយសាបអណាចយសសក្តិខ្មែរក៏បោះបង់ចោលវិជ្ជាគ្រប់ប្រការ ទោះរបស់នោះល្អវិសេសដូចជាប្រាសាទសិលានៅទីក្រុងអង្គរ ក៏ចោលឥតស្តាយស្រណោះឡើយ ។

កាលនៅកុនគ្រាអាប់ចុន ខ្មែរប្រុសដែលចេះអក្សរល្មមមើលសំបុត្របាន មានប្រហែលបីនាក់ប៉ុណ្ណោះ កុងចំនួនដប់នាក់ ។ ឯស្រី ៗ វិញបោះបង់ចោលលែងរៀនអក្សរទាល់តែសោះ ។ កាលបើគេរើសដំរេះ, នៅវេលាជុំផ្ដុំបុត្រាបុត្រីជាគូស្រករ, គេគ្រាន់តែសួរគេដំរេះខាងរកស៊ី គឺឲ្យចេះកាប់សង្រែក បិតដោ ត្បាញល្អ ៗ ឯទីងរើសគេស្រី

ជាករិយាវិញ ស៊ើបសួររកនារីណាចេះដេរប៉ាក់, ចេះការតម្បាញរវៃ, ចេះដណ្តាំស្លប៉ុណ្ណោះ ទុកជាការប្រសើរ ។

ខ្មែរយើង ទើបតែស្រើបចិត្តស្វែងរកបំណេះវិជ្ជាទៀតវិញ ពីត្រឹមរជ្ជកាលព្រះបាទព្រះហរិរក្សរាមាធិបតីព្រះអង្គឌួង ។

ពូរ៍ - អ៊ុម

## ក- ពន្យល់ពាក្យ

នាយកលើ: ជាធំលើ, ជាចៅហ្វាយលើ ។

ប្រាសាទសិលា: ប្រាសាទថ្ម ។

ត្រាអាប់ចុន: គ្រាដុនដាប, គ្រាថោកទាប ។

បុត្របុត្រា: កូនស្រី-ប្រុស ។

ស្រើបចិត្ត: ភ្ញាក់ក្នុងចិត្ត, នឹកឃើញក្នុងចិត្ត ។

រជ្ជកាល: សម័យរបស់ព្រះរាជាគ្រងរាជ្យ (Règne) ។

### ខ- អក្ខរាវិរុទ្ធ

សិលា (សរសេរ ស ស្រៈអិ កុំប្រឡំសីលា)

ផ្សំផ្គុំ (ផ្សំស្រៈអំ ឯផ្គុំស្រៈអុំ)

គូស្រករ (មាន រ នៅចុង)

ស្ងួ (ឥតមាន រ នៅចុងទេ)

រដ្ឋកាល (សរសេរ ដ ជើង ឋ)

### គ- វាក្យស័ព្ទ

អាប់ គុ. (បាញ់គេទាល់តែអាប់មុខ)

អ័ព្ទ ន. (ព្រឹកមិញមេឃចុះអ័ព្ទសន្ធឹកណាស់)

អព្ស គុ. (ការនេះនាំឱ្យអព្សបញ្ញា)

សួរ កិ. (ខ្ញុំសួរទៅកាន់ប្អូនខ្ញុំថា ...)

សួ កិ. (ខ្ញុំឡើងសួលើមែកឈើ)

សួគ៌ ន. (ទេព្ដាកើតនៅស្ថានសួគ៌)

បិត កិ. (គេអង្គុយបិតផ្ដោ)

បិទ កិ. (គេទាញទ្វារបិទឲ្យជិត)

ប៉ាក់ កិ. (ស្រីនេះប្រសប់ដេរប៉ាក់ណាស់)

បក្ស ឬ បក្ខ ន. (កុំនិយាយប្រកាន់បក្សពួក)

## ២៣_ក្អែកបិត្តលោភ

មានក្អែកគោកមួយ អាស្រ័យនៅក្នុងដងព្រៃមួយអន្លើដោយក្អែកមេជាភរិយា ។ ថ្ងៃមួយ ចៅបក្សាណា នាងភរិយាចេញទៅរកអាហារតាមដោយមាត់បឹង ។ លុះទៅដល់បឹងមួយបានឃើញហ្វូងក្អែកទឹកនិងស្មោញទាំងឡាយ ហែលមុជចាប់ត្រីបានបរិភោគរៀងខ្លួន ។ ក្អែកនោះគិតថា ក្អែកទាំងនេះ ក៏ជាបក្សីដូចអញដែរ ហេតុអ្វីក៏គេមុជចាប់ត្រីបាន អញសោតជាក្អែកដូចគេដែរ គួរខ្មាសគេណាស់ ។ បើដូច្នេះ គួរតែអញចុះមុជចាប់ត្រីនឹងគេឲ្យបានអាស្រ័យ កុំឲ្យគេមើលងាយបាន ។

គិតហើយក្អែកគោកសំឡុបស្លាប មុជទឹកធ្វើញាការ

ដូចក្អែកទឹក ខំប្រឹងមុជទៅប៉ះសារាយណែនណាន់ ព័ទ្ធក

ក្អែក ស្រោបកាយ រុំព័ទ្ធប្រាណ ។ ក្អែករើខ្លួនពុំបាន

ឈ្លក់ទឹកដល់នូវមរណកាលកណ្ដាលគង្គាក្នុងគ្រានោះទៅ ។

ឥន្ទ (សុគន្ធប្រីជា)

ក- ពន្យល់ពាក្យ contraire au

ក្អែកគោក : ក្អែករកស៊ីលើគោកផ្ទុយពីក្អែកទឹក ។

ដងព្រៃ : ផ្លូវព្រៃ , ដំបន់ព្រៃ ។

មួយអន្លើដោយ : ជាមួយនឹង, មូលមួយគ្នានឹង ។

ក្អែកមេ : ក្អែកញី, មេក្អែក ។

អាស្រ័យ : បរិភោគ, ស៊ី ។

សំឡុបស្លាប : សង្រួមស្លាប, ដាក់ស្លាបមកជិតខ្លួន ។

មរណកាល : ពេលស្លាប់, សេចក្ដីស្លាប់ ។

កណ្ដាលគង្គា ; កណ្ដាលផ្ទៃទឹក ។

ខ- អក្ខរាវិរុទ្ធ

អាស្រ័យ (ប្រយ័ត្នកុំសរសេរ អាស្រៃ)

បឹង (សរសេរស្រះ អឹ)

ហ្វូង (សរសេរដូចនេះ តែអានថា វ៉ូង)

មុជ (សរសេរ មុ នឹង ជ មិនមែន ច ទេ)

សំឡប ឬ សម្លប (ដាក់បានទាំងពីរយ៉ាង)

អាការ (សរសេរ រ នៅខាងចុង)

ប៉ះ (ប្រយ័ត្នកុំសរសេរប៉ាស់ ឬប៉ាះ)

គង្គា (ប្រយ័ត្នកុំសរសេរគង្គា)

គ- ពាក្យស័ព្ទ

ព័ន្ធ កិ. (កុំយករឿងគេមកព័ន្ធដៃព័ន្ធជើង)

ពាន់ សំ. (ខ្ញុំមានប្រាក់ប្រាំពាន់រៀល)

ពន្ធ ន. (បណ្ដាអ្នកស្រុកបង់ពន្ធឲ្យរាជការ)

ពន់ គុ. (គេកើតទុក្ខពន់ពេកណាស់)

ត្រា ន. (គ្រាណាខ្ញុំត្រូវឆ្នោត ខ្ញុំនឹងទិញផ្ទះមួយធំ)

គ្រាហ៍ កិ. (អ្នកជម្ងឺសុទ្ធតែជួយគ្រាហ៍ទើបដើររួច)

---

## ២៤-វត្តស្រុកស្រែ

នៅក្បែរព្រះវិហារ មានទេវស្ថានបុរាណមួយសង់ពីថ្មបាយក្រៀម ដែលបាក់បែកដោយជរាភាពណាស់ទៅហើយ។ នៅបរិវេណនៃស្ថាននេះ មានទេវរូបនិងបដិមា ខ្លះដាច់ព្រះសិរ ខ្លះបាក់ព្រះហស្តនិងព្រះបាទ រប៉ាត់រប៉ាយ ហាក់ដូចជាបេះពោលប្រាប់យើង អំពីអតីតភាពក្រែកនៃជនស៊ែយសាសន៍។

ពេលដែលខ្ញុំចេញពីវត្តនេះទៅ ព្រះសុរិយាក៏បន្ទាបផិតអស្ដង្គត បញ្ចាំងរស្មីទៅលើជហ្វាងនិក្តារឲ្យក្រៀមព្រាត ៗ ។ ឯសំឡេងព្រះសង្ឃដែលស្វាធ្យាយធម៌ ក៏ឮរំលឹកបន្ទិមាត់មាន់

ព្រៃទឹកតាវ៉ៅ ដែលនាំគ្នាស្រែកហៅចំពោះព្រះអាទិត្យ ។ បន្តិចក្រោយមក សូរព្រះធម៌នេះ នៅតែមានអណ្តែតក្នុងផ្ទៃរាត្រីងងឹតសូន្យ គឺរាត្រីស្រុកព្រៃដែលស្ងាត់ជ្រងំ ហើយដែលក្លិនផ្កាស្រទៀត ឬ ផ្កាព្រហ្មផាត់ក្រអូបភាយ ៗ បណ្តាក់គ្នានឹងសម្រែកខ្លា, សម្រែកដំរី ដែលចេញដើរស្វែងរកអាហារ ។

ដោយវត្តនេះ មានរៀបសំអាតឥតមានមន្ទិល ទីងដោយតាំងនៅកណ្តាលទ្រូងអរញ្ញ ឃ្លាតឆ្ងាយពីសេចក្តីក្រេកក្រអាលនៃមនុស្សផ.តិនោះ អ្នកដំណើរទាំងឡាយក៏ភ្ញាក់យល់ក្នុងចិត្តថា ទីនេះសមជាទីអាស្រមបំពេញសីល-ទាន ប្រកបតាមពុទ្ធោវាទឲ្យបានហ្មត់ហ្មង់ពុំខានឡើយ ។

ឆូ - ហាប

ក- ពន្យល់ពាក្យ

ទេវស្ថានបុព្វណ : អ្នកទេព្តាសង់តាំងពីដើម ។

បរិវេណ : ទំហំដែលមានកំណត់របងព័ទ្ធជុំវិញ ។

ពុទ្ធបដិមា : រូបសំណាកជាអង្គព្រះពុទ្ធ, ពុទ្ធរូប ។

ព្រះសិរ : ក្បាល, សិរសា, ព្រះកេស ។

សៃយសាសន៍ : សាសន៍ដទៃ ។

ជិតអស្តង្គត : ជិតលិចរស្មីទៅខាងលិច ។

អរញ្ញ : ដងព្រៃ, ទ្រូងព្រៃ, ព្រៃជ្រៅ ។

ពុទ្ធោវាទ : ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

១- អក្ខរាវិរុទ្ធ

ក្បែរ គុ. ( មានរនៅចុង )

ក្រៀម គុ. ( សររសេរកជើង រ )

សិរ, សីរ, សេរ ន. (ដាក់បានទាំងបីយ៉ាង)

ជ្រនំ គុ. (សរសេរ ន ស្រៈ អំ)

សីលទាន ន. (សរសេរ ស ស្រៈ អី)

គ– ពាក្យស័ព្ទ

ស្គរ ន. (គេឮស្គរថ្កៀល្ងនៅកណ្ដាលយប់)

ស្បូវ ន. (ព្រះស្បូវរះខ្ពស់ណាស់ហើយ)

ស្វ ន. (ក្មេងនេះពាក់ខ្សែស្វនៅក)

---

## ២៥– ពុទ្ធសាសនានិងវិទ្យាសាស្ត្រ

បណ្ដាចំណេះវិទ្យាសាស្ត្រនីមួយៗពុទ្ធសាសនា ត្រូវតែនាំមកពន្យល់នៅទីចំពោះមុខនៃប្រជុំជនទាំងឡាយទើបស្ដាប់ ទើបយល់សេចក្ដីនៃវិជ្ជាទាំងពីរច្បាស់ណាស់ ។ ប៉ុន្តែបើតាមយោបល់របស់អ្នកប្រាជ្ញគង់គ្រួសម្នាក់ បានតែងសៀវភៅមួយនិយាយពីប្រវត្តិរបស់ព្រះពុទ្ធ ហៅថា "ប្រទីបទ្វីបអាស៊ី" ។

សៀវភៅនេះនិយាយពីគោលសំខាន់ៗ នៃព្រះពុទ្ធសាសនា ទាំងយោបល់នឹងគំនិតគិតឃើញ ជារបស់អ្នកនៅទិសខាងលិច ។ កាលបើគេបានជ្រួតជ្រាបលទ្ធិពុទ្ធសាសនាហើយ ក៏អាចរលាយចូលគ្នាបាននឹងលទ្ធិយោបល់ របស់អ្នកនៅទិសខាងកើតបាន ។ ហើយក្លាយទៅជាវិជ្ជាចំណេះរបស់អ្នកនៅទិសខាងលិចទៅវិញ សេចក្តីពិតមិនមែនសោះឡើយ ។ ព្រោះសាសនាមិនមែនជាវិទ្យាសាស្ត្រទេ គ្រាន់តែជាគោលសិក្សា ព្រមទាំងការប្រតិបត្តិដោយម៉ឺងម៉ាត់ ដើម្បីធ្វើជីវិតរបស់មនុស្សឲ្យប្រព្រឹត្តទៅបានស្រួលប៉ុណ្ណោះ ។

ញ៉ុក-ថែម

ក- ពន្យល់ពាក្យ

ពុទ្ធសាសនា: ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

វិទ្យាសាស្ត្រ: ក្បួនច្បាប់វិជ្ជា, វិជ្ជារិះរក, វិជ្ជាស្រាវជ្រាវ

ប្រវត្តិ: សាវតារ, រឿងរ៉ាវសាវតាកំណើត ។

អ្នកនៅទិសខាងលិច : (Pays Occidental) ។

អ្នកនៅទិសខាងកើត : (Pays Oriental) ។

ប្រទីបអាស៊ី : (La lumière de l'Asie) ។

គោលសិក្សា : ទ្រឹស្ដី (Théorie) ។

ការប្រតិបត្តិ : ការអនុវត្តន៍ (Application) ។

១ - អក្ខរាវិរុទ្ធ

ក្លាយ (សរសេរ ក ជើង ល )

មុឺនម៉ាត់ ឬ ហ្មឺនហ្មត់ (ដាក់បានទាំងពីរបែប)

ជីវិត (សរសេរ ជ ស្រៈ អី, វ ស្រៈ អិ)

គ – ពាក្យស័ព្ទ

សាស្ត្រ ន. ( វិទ្យាសាស្ត្រ, អក្សរសាស្ត្រ )

សាសន៍ ន. ( សាសន៍ខ្មែរ. សាសន៍ចិន )

សះ កិ. ( ដំបៅជាសះមែនទែនហើយ)

កើត ន. ( ព្រះអាទិត្យរះខាងឯកើត )

កើត ន. ( ថ្ងៃនេះជាថ្ងៃ៣កើតខែបុស្ស )

កើត កិ. ( ស្ត្រីនេះទើបកើតបានកូនមួយ )

ប្រតិបត្តិ ន. ( រាជការដាក់ច្បាប់ឲ្យរាស្ត្រប្រតិបត្តិ )

ប្រណិបតន៍ ន. ( សិស្សត្រូវប្រណិបតន៍គ្រូអាចារ្យ )

---

## ២៦ - ទឹកល្បប់

ហ៊ៀ ! ហ៊ៀ ! ហ៊ៀ ! មិនដាច់សូរ ៗ សន្ទឹកព្រឹក្សាមិនមានកម្រើកឡើយ ៗ ទេសភាពជិតខាងស្ងាត់ក្នុងសភាពស្ងប់ស្ងៀមដូចត្រូវស្ពឹកស្ពន់ ៗ មេឃពោរពេញ, ស, ក្រហមគាំងហ្វូងនាំគ្នាហើរវិលរើកតាមចន្លោះផ្ការ ៗ សត្វល្អាចេកហួបត្រូវគេ ៗ កន្ទុំគុម្ពដើមឈើ ៗ កំពូលកំពណ៌ផ្ទៃមេឃខ្ពស់ នៅឯឆ្ងាយមើលទៅឃើញលិច ៗ ទឹកហូរចេញពីជ្រោះក្តី បង្កើតជាអូរដែលមានតែដំណើរធម្មជាតិកើតឡើងដោយការតម្រៀបមិនត្រឹមស្មើនៃដុំសិលា ៗ

ឱទឹកហូរអើយ ! អ្នកមានដើមកំណើតមកពីណា ... ជាទេពនិមិតទេដឹងដែលបណ្ដាលឲ្យអ្នកត្រជាក់ស្រិបដូច្នេះ ។ អ្នកដំណើរតែងនាំគ្នាបណ្ដោតកាយលេង ឬ វារបុះវារឡើង សើចក្អាកក្អាយ ( សែនក្សេមក្សាន្តក្នុងចិន្តា ) ហាក់បីដូចជាហ្វូងកិន្នរក្នុងគន្ធរ្វដែលកំពុងតែលេងទឹក អនោតស្រះនៃស្ថានកៃលាស ។

ឈូ ! ឈូ ! សូរទឹកហូរគ្មានអាក់ សមនឹងឈ្មោះថា «ទឹកឈូ» មែន ។

អ៊ុម - ឈូដេត

ក— ពន្យល់ពាក្យ

ទេសភាព: សភាពរបស់ស្រុក (Paysage) ។

ដើមគង្គា : ឈ្មោះដើមឈើមួយគេយកតាំងជាលំអរ ។

ជណ្ដើរធម្មជាតិ : ជណ្ដើរដែលកើតឯង ។

ទេពនិមិត : ទេវតាកាឡា ឬទេវតាជំណែង ។

ក្សេមក្សាន្តក្នុងចិន្តា : សុខសាន្តប្ដីកែពយក្នុងចិត្ត ។

អនោតស្រះ : ឈ្មោះស្រះធំមានទឹកត្រជាក់មិនចេះត្រូវ

កំដៅ ។

ស្ថានកៃលាស : ឈ្មោះភ្នំពិសេសមួយក្នុងចំណោមភ្នំ

ហិមពាន្ត ។

១- អក្ខរាវិរុទ្ធ

កម្រើក ឬ កំរើក (សរសេរបានទាំងពីរយ៉ាង)

ស្ថិត ឬ ឋិត (សរសេរបានទាំងពីរយ៉ាង)

គុម្ព (សរសេរ ម ជើង ព)

ស្បូរ (មាន រ នៅចុង)

វារ (មាន រ នៅចុង)

ក្សេមក្សាន្ត (កុំសរសេរ ខ្សេមខ្សាន្ត)

កិន្នរ (ប្រយ័ត្នកុំសរសេរ កេណារ ឬ កិណ្ណារ)

គ- វាក្យស័ព្ទ

សិលា ន.( ទឹកហូរបោកលើដុំសិលា )

សីលា ន.( សីល ) (តាបសឬសីកាន់សីលា )

កាយ ន.( គេបណ្តែតកាយលេងតាមទឹក )

កាយ កិ.( គេកាយដីចេញពីរណ្តៅ )

អាក់ កិ ( ទឹកហូរគ្មានចេះអាក់ )

អាក់ ន.( គេការសូត្រដាក់ក្នុងអាក់ )

---

## ២៧ - ផលប្រយោជន៍នៃផ្លូវទឹក

ដោយភូមិស្រុកខ្លះនៅតាមមាត់ទន្លេដែលមិនមានដីគ្រើយជាប់គ្នា ទន្លេក៏ជាផលមគ្គ ឬ ជាគមនាគមន៍សំរាប់ធ្វើដំណើរប្រសើរលើសលប់មួយដែរ ។ ក្នុងរដូវវស្សាទឹកទន្លេឡើងពោរពេញលំហារ បណ្តាលឲ្យហូរបង្កើតជាល្បឿន

លោកទឹកឃ្លាំងខ្ញុំ ។ ទឹកហូរទឹកលោកដែលជួបទៅប្រាំង ទន្លេ ព្រោះដីតាមមាត់ប្រាំង ក្លួចយកទៅបាតទន្លេកើតជា គម្រល្អក់ស្ទូងតែដីម៉ដ្ឋ ។ កករទឹកនេះ គេហៅថាល្បាប់ ដែលទន្លេនាំមកចាក់នៅញម្មនៅមាត់ប្រាំង, មាត់ព្រែក កងវេលាទឹកជំនន់ជោរខ្ញុំមក ។ ដីល្បាប់នេះឯងជាដីជាតិ ប្រសើរក្រៃលែងចំពោះផលដំណាំកងចំការនានា ដែលនៅ ក្បែរមាត់ទន្លេ ។

ត្រីដែលជាអាហារសំខាន់របស់យើងក៏កើតមកដោយ សារទឹកទន្លេដែរ ។ រាល់ៗឆ្នាំ អ្នកនេសាទបានចាប់ត្រីពី កងទន្លេទាំងនេះរាប់ម៉ឺនសែនគ្រាល លក់ចំណាយទៅគ្រប់ ទិសទីកងប្រទេសនិងក្រៅប្រទេសទៀត ។ ក្រៅពីនេះ ទន្លេអាចផ្តល់ទឹកឲ្យអ្នកធ្វើចំការបញ្ជាដំណាំយើងបានផលគ្រប់ គ្រាន់ផង ។

ហេតុនេះ ទន្លេជាផលប្រយោជន៍យ៉ាងចំណានរបស់ប្រទេស ។

ណាត - ហាត់អាន

ក - ពន្យល់ពាក្យ

ជលមគ្គ : ផ្លូវទឹក, ជលធារ (Cour d'eau) ។

គមនាគមន៍ : ការធ្វើដំណើរទៅ - មក (Communication) ។

រដូវវស្សា : រដូវទឹកជំនន់,រដូវភ្លៀង(Saison de pluie)

ពាម : កន្លែងមាត់ព្រែក, ទីមានព្រែកភ្ជាប់នឹងទន្លេ ។

១ - អក្ខរាវិរុទ្ធ

ពោរពេញ (មាន រ នៅពីមុខពោ)

លំហរ (មាន រ នៅខាងចុង)

ហូរ (មាន រ បើហៅគ្មាន រ ទេ)

កួប (សរសេរ ក ស្រៈ អួ)

ម៉ដ្ឋ (ប្រយ័ត្នកុំសរសេរម៉ត់)

ជោរ (មាន រ នៅចុង)

ជីជាតិ (ឥតមាន រ ទេ)

ដោយសារ (មាន រ នៅចុង)

ច្បារ (មាន រ, កុំច្រឡំផ្កាច្បា)

គ- ពាក្យស័ព្ទ

ច្រាំង ន. (ច្រាំងមាត់ទន្លេបាក់ណាស់)

ជ្រាំង ន. (ក្មេងកើតជ្រាំងពេញមាត់)

ច្រោះ កិ. (ទឹកច្រោះដីឲ្យហូរចេញអស់)

ជ្រោះ ន. (ទឹកស្ទឹងហូរមកពីជ្រោះភ្នំ)

ជី ន. (ដាំបន្លែត្រូវដាក់ជីផង)

ជីរ ន. (ចូរបេះស្លឹកជីរមកជ្រក់ត្រីស្ងោរ)

ជី ន. (ខ្សែដៃនេះទម្ងន់មាស៣ ជី)

# ២៨- បុត្រីមានគុណធម៌

កម្មករពេនបត្រម្នាក់ នៅពោះម៉ាយ ជាយូរឆ្នាំមកហើយៗ ប្រពន្ធគាត់ស្លាប់បាត់បង់ទៅ ទុកកូនស្រីមួយឲ្យបីថែរក្សា ។

ថ្ងៃមួយកម្មករនេះ កំពុងតែប្រកបការដូចគ្រាជម្មតា ស្រាប់តែគ្រឿងចក្រនោះផ្ទុះឡើង បណ្តាលឲ្យមានគ្រោះថ្នាក់ដល់ភ្នែកគាត់ទាំងពីរ ងងឹតលែងមើលអ្វីឃើញតាំងពីថ្ងៃនោះមក ។ គាត់ត្រូវតែដើរធ្វើស្មូមយាចក ដើម្បីសុំនូវសប្បុរសធម៌ពីជននានាសំរាប់ចិញ្ចឹមជីវិតគាត់ និងកូនស្រីគាត់នៅតូចៗ ។ រាល់ថ្ងៃ កុមារីនេះ តែងនាំបិតាទៅផ្អាក់ឲ្យអង្គុយកន្លែងណាដែលមានមនុស្សច្រើន ហើយខ្លួននាងលបទៅរៀនអក្សរឯសាលា មិនឲ្យឪពុកដឹងឡើយ ។ បុត្រីសេដ្ឋីឯទៀត តែងនាំគ្នាពោលដៀលត្មះនាងថា មេកូនអ្នកសុំទាន, តែនាងឥតឆ្លើយតបសោះ ។

ព្រឹកមួយនោះ ជាថ្ងៃប្រឡងវិញ្ញាបនបត្រ នាងបានដឹកដៃឪពុកពិការទៅដាក់កន្លែងសុំទានដូចសព្វដង រួចនាងប្រញាប់ប្រញាប់ទៅចូលប្រឡងជាមួយគេ ។ ប្រាំបីថ្ងៃក្រោយមក នាងបានទទួលលទ្ធផលល្អត្រកាល ហើយរត់ម្នីមាទៅរកឪពុក ។ នាងលោតទៅឱបកមនុស្សពិការ ហើយពោលថាៈ ពុក! ចាប់ពីថ្ងៃនេះទៅ យើងលែងសុំទានគេទៀតហើយ កូនទើបនឹងប្រឡងជាប់វិញ្ញាបនបត្រ ។ កូននឹងចេញធ្វើជាគ្រូយកប្រាក់ខែចិញ្ចឹមពុក កុំឲ្យពុកដើរសុំគេ, ស្លៀកពាក់កណ្ដាចប្រៀកជៀតដូច្នេះទៀត ។

លី-ធាមតេង

ក-ពន្យល់ពាក្យ

កម្មករពេនបក្រ : អ្នកធ្វើការកងពេនម៉ាស៊ីន ។

សមយាចក : អ្នកសុំទាន, មនុស្សសុំទានគេ ។

សប្បុរសធម៌ : ធម៌សប្បុរស, សេចក្ដីសប្បុរស ។

វិញ្ញាបនបត្រ : ឈ្មោះសញ្ញាបត្រមួយយ៉ាង(Certificat) ។

លទ្ធផល : ផលដែលបានសំរេចជាចំផុត(Résultat) ។

ជ្រៀកជៀត : រហែករយ៉ែដូចជាធ្វើជៀតត្រី ។

១– អក្ខរាវិរុទ្ធ

ជៀលគ្នះ : (កុំសរសេរ ជៀលគ្និះ ឬ ជៀលថ្នាស)

បិតា : (ប្រយ័ត្នកុំប្រឡំ សរសេរ បីតា ឬ បីដា)

ប្រៀកជៀត : (សរសេរ ប ជើង រ)

គ – វាក្យស័ព្ទ

បក្រ ន. ( នាវិសម័យប្រើសុទ្ធតែគ្រឿងបក្រ )

ចាក់ កិ. ( អញ្ជើញគ្រូពេទ្យមកចាក់ថ្នាំ )

ច័ក្ខុ (អ.ថ.ចាក់) ន. ( ព្រះឥន្ទ្រាបើកទិព្វច័ក្ខុ )

រត់ កិ. ( ក្មេងរត់ប្រណាំងគ្នា )

រតន៍ ឬ រត្ន ន. ( រតន៍ប្រែថាពេជ្រ ឬ កែវ )

រដ្ឋ ន. ( ខ្ញុំនៅក្នុងរដ្ឋកម្ពុជា )

រថ ន. ( ព្រះរាជាគង់លើរថទឹមសេះ )

---

## ២៩_ ខួរក្បាល

ខួរក្បាលជាសាច់ទន់ភ្លន់ល្វន់ល្វៃ ប្រហែលនឹងសានផុរេន យ៉ាងធំ មានទំហំតូចជាងក្បាលរបស់ម្ចាស់ខ្លួនបន្តិច មានទម្ងន់ប្រមាណមួយពាន់ប្រាំរយក្រាម ។ ឯខ្នាតខួរក្បាលធំ ឬ តូច មានទម្ងន់ធ្ងន់ ឬ ស្រាលមិនមែនជាគ្រឿងវាស់សេចក្ដីល្ងង់ខ្លៅឆ្លៀវឆ្លាតទេ ព្រោះមនុស្សមានក្បាលធំ មានខួរច្រើន តែជាមនុស្សល្ងង់ខ្លៅក៏មានគួរគាគ ។ ឯសេចក្ដីល្ងង់ឆ្លាតនៅត្រង់សាច់របស់ខួរក្បាលដែលមានសណ្ឋានល្អ ឬ អាក្រក់មកពីកំណើត ។ ហេតុនេះទើបឃើញថា ខួរក្បាលល្អមានទំនងដូចសំពត់សាច់ម៉ដ្ឋប្រើជាប់បានយូរ ។

resemble

ខួរក្បាលនេះ ជាអវយវៈសំខាន់បំផុតរបស់រាងកាយ ជាអធិបតីស្តីការលើសរីរយន្តទាំងពួងក្នុងរាងកាយ មានទំនងដូចមន្ត្រីស្តីការក្នុងក្រសួងនិមួយ ៗ ដែរ ។ ប្រសិនបើខួរក្បាលពិការទៅ ឬ អធិបតីនោះស្តីការមិនត្រឹមត្រូវ មុខជាការងារទាំងពួងនឹងកើតវវឹកផ្តេសផ្តាស ទៅតាមគ្នាទាំងអស់មិនខាន ។ Tầm bậy - Tầm bạ

ញ៉ែក - ថែម

ក- ពន្យល់ពាក្យ

ល្វន់ល្វៃ : ដែលទន់វឹកវ៉ក់មិនបេះនៅនឹង ។

សណ្ឋាន : បែបបទ, រាងរៅ, សភាព ។

អវយវៈ : : គ្រឿងប្រដាប់របស់រូបកាយមនុស្ស ។

អធិបតី : ជាធំលើគេ, ជានាយចៅហ្វាយគេ ។

សរីរយន្ត : គ្រឿងបត្រនៃរូបរាងកាយ ។

ស្តីការ . ត្រួតត្រាការ, ចាត់ចែងការ ។

១- អក្ខរាវិរុទ្ធ

ខ្សែ (សរសេរមាន រ នៅចុង)

ទំហំ (សរសេរ ទ ស្រៈអំនឹងហស្រៈអំ)

គរគោក (ត្រូវមាន រ មួយពីមុខ គ)

ម៉ដ្ឋ (ប្រយ័ត្នកុំសរសេរ ម៉ត់)

អវិយវៈ (មានយុគលពិន្ទុតែពីមុខ វ ចុងបង្អស់)

និមួយ ៗ ឬ នីមួយ ៗ (ដាក់បានទាំងពីរបែប)

វិរក (សរសេរ វ មានរ, វ ស្រៈអិនឹងក)

ផ្ដេសផ្ដាស (កុំសរសេរផ្ដេះផ្ដាស់)

គ-វាក្យសព្ទ

ទន់ គុ. (ដីត្រង់នេះទន់ណាស់ព្រោះត្រូវទឹក)

ទាន់ កិ.វិ. (គេរត់ដេញទាន់ចោរ)

ទន្ត ន. (លោកគ្រូបាក់ព្រះទន្តអស់ហើយ)

ទ័ណ្ឌ ន. (យក្សត្រូវទ័ណ្ឌរួចហោះឡើងទៅ)

ម៉ដ្ឋ គុ. (ម្សៅមីម៉ដ្ឋល្អណាស់)

ម៉ត់ កិ.វិ. (ឆ្កែស៊ីម៉ត់ឈាប់ជ្រូកលើជ្រុំ២)

ហ្មត់ ឬ ម៉ត់ (ធ្វើចិត្តហ្មត់ចត់ឲ្យហ្មត់ហ្មង)

---

## ៣១–ទេសភាពមាត់សមុទ្រ

រស្មីព្រះសុរិយារសៀលមោងបួន កំពុងបណ្ដើររន្ទះពេជ្ររលិប ៗ ផ្លេក ៗ លើផ្ទៃជលសា ឯនាយសមុទ្រជាប់នឹងជើងមេឃឯនោះ ៗ បន្ទាប់មកគឺផ្ទាំងសំពត់ផាមួងកទាដែលខៀវស្រងាត់ ហើយដែលយូរ ៗ គេឃើញមានក្លើងពិលសស្គុះបាំងភ្លែត ៗ ចេញពីផ្ទាំងសំពត់ព្រៃនោះម្ដង ៗ ៗ នេះហើយគឺរលកបែកផ្កាត្រែង កើតឡើងពីការប៉ះទង្គិចរវាងដុំរលកនឹងដុំសិលាដែលដុះកណ្ដាលសមុទ្រ បណ្ដាលឲ្យបែកទឹកខ្ចាយសំពោងមើលទៅឃើញសស្គុះ ហាក់បីដូចជាផ្កាត្រែង ៗ ។

កោះតាយ ឬ កោះទន្សាយពងខ្ញីកំប៉ុកដែលនៅខាងត្បូង មើលទៅឃើញយ៉ាងច្បាស់ជិតបង្កើយ ។ ព្រះអាទិត្យបេះ តែថយរស្មីជាលំដាប់ ។ ខ្យល់ដំនោរក៏ចាប់ផ្ដើមប្រគំតូរ្យតន្ត្រី ហ៊ឺៗ មិនដាច់សូរ ។ ដើមដូងបញ្ឈរដើមស្រោងស្រឹងក៏ ទន់ទោរទៅកាន់មាត់ទឹក រណាស់តែចុងធាងនឹងចុងស្លឹករវិច ៗ ហាក់ដូចជារាំ ។ ឯរលកនៅតែប្រឆាំងនឹងដុំសិលាក្រោម ជើងទេរ ឮសូរឆាវ ៗ ជានិច្ច ។

អ៊ុម - ឈូដើត

ក- ពន្យល់ពាក្យ

ប្រគំតូរ្យតន្ត្រី: លេងភ្លេង, លេងបញ្ចេញសូរភ្លេង ។

ជើងទេរ : ដីច្រាំងដែលជម្រាលនៅមាត់ទឹក ។

ផាមួង កុទា : ឈ្មោះពណ៌ខៀវក្រមៅស្ទើរបៃតង ។

សើប ៗ : ដែលល្ហើបល្ហើល ឮសូរស្រើប ៗ ។

ផ្ទៃជលសា : ផ្ទៃទឹក, ផ្ទៃសមុទ្រ ។

ខ-អក្ខរាវិរុទ្ធ

ស្រងាត់ (អ. ថ ស្រងាត់)

ច្បាស់ (ប្រយ័ត្នកុំសរសេរ ច្បាះ ឬ ច្បះ)

ដំណោរ (មាន រ នៅខាងចុង)

ផ្ដើម (កុំសរសេរ ប្ដើម)

តូរ្យតន្ត្រី ឬ ដូរ្យតន្ត្រី (សរសេរបានទាំងពីរយ៉ាង)

បញ្ជ្រ (សរសេរញជើងឈ ទីង រ)

ទេរ (មាន រ នៅចុង)

គ- វាក្យសព្ទ

ពេជ្រ ន. (ត្រីម្នាក់ពាក់បណ្ដោងពេជ្រ)

ពេចន៍ ប. (ពាក្យពេចន៍ក្នុងនេះល្អគ្រាន់បើ)

រលក ន. (រលកទឹកបោកផាងច្ចូ)

លលក ន. (លលកយំឆ្លើយឆ្លងគ្នា)

ទេរ គុ. ( ដើមត្រំដុះនៅដីជើងទេរ )

ទេ (ខ្ញុំមិនយល់ទេរឿងនេះ)

ចាំង កិ. ( ព្រះអាទិត្យចាំងរស្មីយ៉ាងខ្លាំង )

ចាំង កិ. ( ដាងឈើកំពុងចាំងសសរ )

ចាំង ន. ( គេធ្វើនំចាំងបានបីចង្កោម )

---

## ៣២- ការបោះបង់ចោលក្រុងអង្គរ

កាលពីដើមសតវត្សទី ១៥ ព្រះអតីតមហាក្សត្រខ្មែរ ព្រះនាមស្រីសុរិយោពណ៌ទី ២ ចៅពញាយ៉ាត បានទ្រង់ព្រះតំរិះលើករាជធានីពីក្រុងអង្គរមកតាំងនៅទន្លេបួនមុខវិញ ។ បានជាទ្រង់សព្វព្រះរាជហឫទ័យលើកទីក្រុងនេះ ដោយព្រះអង្គទ្រង់ឈ្វេងយល់ថា ទីក្រុងចាស់ស្ថិតនៅក្បែរប្រទេសសៀម

ដែលបច្ចាមិត្រសម័យនោះពេកណាស់ ។ ប្រសិនជាកើតចម្បាំងពាំងដល់ឡើង យើងពិបាកនឹងចាត់ការទប់ទល់ការពារជាពន់ពេក ។

ថ្ងៃមួយ ដែលក្រុមហោរាបានសន្មតទុកជាពេលប្រកបដោយនក្ខត្តឫក្សជោគជ័យសិរីមង្គល , ព្រះរាជា មួយអង្គដោយរាជបរិពារ បានយាងចុះគង់លើព្រះទីនាំងនាវាចេញចាកទីក្រុងចាស់ ប្រកបដោយទឹកព្រះទ័យអាឡោះអាល័យក្រៃលែង ។ ក្បួនដង្ហែព្រះនរបតីបានលៀនសន្សឹមៗកាត់ទន្លេសាប សំដៅមានទូកដ៏អុំប្រទក្សិណ ស្រែកជយោថ្វាយជ័យព្រួតនាំពេញផង ។

យើងគួរចាំថា គឺព្រះបាទចៅពញាយ៉ាតនេះហើយដែលទ្រង់លើកទីក្រុងមកតាំងនៅទន្លេចតុមុខជាដំបូងបំផុត ។

លី-ធាមតេង

7



ក— ពន្យល់ពាក្យ

សតវត្ស : រយៈកាល ១០០ ឆ្នាំ (Siècle) ។

អតីតមហាក្សត្រ : ស្ដេចជាន់មុន, ព្រះរាជាជាន់ដើម ។

ទន្លេចតុមុខ : ទន្លេបួនមុខ ។

បច្ចាមិត្រ : មិនមែនជាមិត្ត, សត្រូវ ។

នក្ខត្តឫក្ស : ថ្ងៃដែលប្រកបដោយកំឡាំងផ្កាយ ។

រាជបរិពារ : រាជបរិវារ, ពួកពលរបស់ក្សត្រ ។

ព្រះទីនាំងនាគ ; ជំនិះទូករបស់ក្សត្រ ។

១- អក្ខរាវិរុទ្ធ

ចតុមុខ ឬ ចតុម្មុខ (ដាក់បានទាំងពីរយ៉ាង)

ហឫទ័យ ឬ ហ្ឫទ័យ (ដាក់បានពីរបែប)

ក្បែរ (សរសេរមាន រ នៅចុង)

ការពារ (កាមាន រ , ពាមាន រ )

ក្រុម ឬ ក្រុំ (ប្រយ័ត្នកុំសរសេរ ក្រំ ឬ ក្រុំម)

សន្ទូត (ឥតមាន រស្យសញ្ញាទេ)

នរបតី (អ.ថ.នរប៉ប៉ដី)

គ- ភិក្យស័ព្ទ

សព្វ (សព្វថ្ងៃ, សព្វព្រះរាជហឫទ័យ)

សព ន. (គេដម្កល់សពលើជើងថ្ករ)

សប់ កិ. (គេសប់កង់ឡានឲ្យប៉ោង)

ផល់ កិ. (ផល់ជើងនឹងថ្ម, ចម្បាំងរាំងផល់)

ផល ន. (ផលនេត្រហូរហៀរពេញភក្ត្រា)

---

## ៣៣- កសិករនិងបុត្រ

ក្រោយដែលដឹងថាខ្លួននឹងដល់នូវមរណកាលក្នុងពេលឆាប់ ៗ ខាងមុខនេះហើយ កសិករចាស់ម្នាក់បានហៅកូនមកជុំគ្នា ផ្ដាំថា៖ បើឥតអំពីឪពុកទៅ ដីស្រែជាកេរ្ដិ៍ដែល

ឪពុកទុកឲ្យទាំងប៉ុន្មានឯងមិនត្រូវលក់ទេ ដ្បិតក្នុងដីនេះមាន កំណប់ដ៏មានតម្លៃជាច្រើន ។ ផ្តាំរួចកសិករជរាក៏ទំលាយខ្លួន ទៅកាន់បរលោកទៅ ។

កូនទាំងអស់ បានចាំនូវពាក្យបណ្ដាំរបស់ឪពុក ក៏ បបួលគ្នាកាន់ចបកាប់, ចបជីក, ចបចែល តម្រង់ទៅកាន់ ដីស្រែ ហើយកាប់គាស់ជីកជ្រួយសុសសាយសឹងតែគ្មាន ចន្លោះ ដើម្បីរកកំណប់ដ៏មានតម្លៃដែលឪពុកប្រាប់នោះ ។ ទោះជាប្រឹងកាប់គាស់ត្រាតែសាយសព្វយ៉ាងណា ក៏ពុំប្រទះ នឹងកំណប់សោះ, ទាល់ប្រាជ្ញាអស់សង្ឃឹមក៏នាំគ្នាលីចបនឹង ប្រដាប់ប្រដាត្រឡប់មកកាន់លំនៅរៀងខ្លួនវិញ ។

លុះដើមឆ្នាំ ក្រៀងឧរកាលណា បុត្រកុដុម្ពិក៏ នាំ គ្នាចាប់ប្រកបការកសិកម្មតាមធម្មតាតែសព្វខ្លួន ។ ដល់ ចុងឆ្នាំកាលណា ស្រូវបានផលពេញជង្រុក លក់បាន ប្រាក់ច្រើនក្រាស់ក្រៃ ទើបដឹងខ្លួនថាៈ បណ្ដាំឪពុកមិន

ខុសទេ ។ គាត់ជាព្រឹទ្ធាចារ្យបានពោលពាក្យជាអាថ៌ប្រស្នា ទុកឲ្យកូនដោះស្រាយជាក្រោយ ។

លី-ណាមតេង

ក- ពន្យល់ពាក្យ

មរណកាល : ពេលស្លាប់, កាលវេលាអស់ជីវិត ។

កសិករ : អ្នកគួររពស់, អ្នកធ្វើស្រែចំការ ។

ទំលាយខន្ធ : ផុតអាយុ, អស់សង្ខារ ។

បរលោក : លោកដទៃ, ភពដទៃ ។

កសិកម្ម : ការងារគួររពស់, កិច្ចការអ្នកស្រែ ។

ព្រឹទ្ធាចារ្យ : គ្រូពីបុរាណ, គ្រូជាន់ចាស់ ។

អាថ៌ប្រស្នា : ពាក្យសំរាប់ដោះស្រាយដ៏មានជម្រៅ ។

ខ- អក្ខរាវិរុទ្ធ

មរណកាល (អ.ថ. មរណៈកាល)

គីគា (សរសេរ គ ជើង ន)

ដម្លៃ ឬតម្លៃ ឬ ដំឡៃ (ដាក់បានដូចគ្នា)

សន្សឹម (សរសេរដើនយស្រៈអឹ)

ប្រដាប់ប្រដា (គ្មានរនៅចុងទេ)

ក្រាស់ក្រៃ (ក្រាស់សរសេរស មានស្រសញា)

អាថ៌ (សរសេរ ថ មានរបាទពីលើ)

គ. វាក្យស័ព្ទ

ដោះ កិ. (បញ្ហានេះត្រូវតែដោះស្រាយ)

ដោះ កិ. (ពួកចោរដោះប្លន់ព្រៃអស់)

ដោះ ន. (កូនក្មេងកំពុងបៅដោះ)

ដស់ កិ. (គេដស់ជាយចេញពីក្នុងថ្នាំង)

---

## ៣៤- ភ្នំភ្លើង

ភ្នំភ្លើងមានសភាពទ្រង់ទ្រាយដូចភ្នំធម្មតាដែរ តែមានប្រហោងខាងកងធ្លុះចេញទៅកំពូល ដែលគេហៅថារន្ធភ្នំភ្លើង ។ រន្ធនេះមានជម្រៅរហូតដល់ផ្ចិតស្នូលផែនដី ។

កាលណាដល់វេលាភ្នំទឹងចាប់ឆេះ ផ្សែងដែលមានហុយចេញពីកណ្ដាលភ្នំយូរមកហើយនោះ វិនាសលែងមានហុយ ៗ ខណៈនោះ បរិវេណដីជិតភ្នំចាប់រញ្ជួយ គេឃើញផេះទឹងវត្ថុរាវដូចបបរ ផុះចេញតាមមាត់រន្ធពីក្នុងដីមកពាសពេញខាងក្រៅ ៗ វត្ថុរាវនេះក្ដៅមហិមា ហូរចុះទៅទីវាលដូចជាស្ទឹងព្រែកនានា ហើយវត្ថុនេះឲ្យគ្រោះថ្នាក់ជាច្រើន កាលបើហូរទៅប៉ះរបស់អ្វី ឬ ភូមិស្រុក បណ្ដាលឲ្យរលាយខ្សុរ ៗ

វេលាយប់ វត្ថុរលាយនេះបញ្ចេញពន្លឺក្រហមឆ្អៅដូចដុំដែកកំពុងឆេះ ៗ លុះយូរមក កាលបើបាត់ក្ដៅ វត្ថុរាវក៏ត្រជាក់កកកើតបានជាថ្មមានពណ៌ខ្មៅល្អជាច្រើន ៗ

ពិតមែនតែភ្នំភ្លើងបង្កើតគ្រោះថ្នាក់ តែមានឲ្យប្រយោជន៍ច្រើនដែរ ក្រោយពេលដែលរលត់ត្រជាក់ទៅ ៗ គេនាំគ្នា

ទៅកាប់គាស់រកវត្ថុធាតុដើម ដ៏មានតម្លៃដូចជាលោហធាតុ មានមាសជាដើម ។

ណាង-ហាប់អាន

## ក-ពន្យល់ពាក្យ

វត្ថុធាតុ : គ្រឿងប្រដាប់សំរាប់ផ្សំ, (Elément) ។

លោហធាតុ : ជាតិរឹងកើតពីក្នុងដីដ៏មានមាសជាដើម ។

### ១- អក្ខរាវិរុទ្ធ

ផ្ចិត (ប្រយ័ត្នកុំសរសេរ ផ្សិត)

រន្ធ (កុំសរសេរ រន់ ឬ ពន់)

ខណៈនោះ (មានយុគលពិន្ទុនៅមុខណ)

ផេះ (កុំសរសេរ ផេស)

ខ្យុរ (អ.ថ. ខ្យុល តែសរសេរ រ នៅចុង)

លោហធាតុ (អ.ថ. លោហៈធាតុ)

មាស (ប្រយ័ត្ន កុំសរសេរ មាស់)

គ-ពាក្យសព្ទ

ព្រាយ ប.( មានទ្រង់ព្រាយដូចភ្លុកម្ដាយ )

ព្រាយ ន.( សត្វព្រាយរត់កាត់ព្រៃ)

វន្ទ ន.(ស្រមោចដឹកឆ្លងបំណាំដាក់ក្នុងវន្ទ)

ភន់ គុ.(ធ្វើការកុំភន់ពេក)

ប៉ះ កិ.(គេដើរប៉ះគ្នា )

ប៉ាស កិ.( ដាក់ប៉ាសកង់ឡាន )

ពិត គុ.( ការនេះទុកជាការពិត)

ពិត កិ.(ពិតខ្នងនឹងជញ្ជាំង )

ពិត ន.(បិនកាន់ពិតសរសេរអក្សរ)

ពិធ ន,(ត្រីពិធសម្បត្តិ)

---

# ៣៥-ឆ្នេរជិលសា

ទេសភាពប្រែភេទយ៉ាងជាក់ស្តែង សន្ទឹកព្រឹក្សាយ៉ាងស្តុកស្តម្ភហើយខៀវស្រស់ គ្របដណ្តប់ជុំជិតទីដីវាលទឹងគម្លាតក្នទាំងអស់ មានតែទីដីស្រែអំបិលប៉ុណ្ណោះទេ ដែលមើលទៅឃើញក្រហមស្រគាំ ៗ លាយទឹងផ្កាំងទឹកប្រៃដែលសស្គុះនោះ ៗ ជង្រុកអំបិល មើលទៅឃើញរគេគរគូតជាប់ ៗ ពីគ្នា ។

នេះហើយ ជាភូមិភាគកំពត ។ នៅចន្លោះកណ្តាលនៃទេសភាពទាំងសងខាង ដែលខៀវស្រស់នោះ ជងមាត់ជាក់កៅស៊ូត្រូវទឹងវន្ទះព្រះសុរិយា មើលទៅឃើញសស្កុងដូចជាកម្រាលប្រាក់ លាតសន្ធឹងតម្រង់ទៅរកក្នំពណ៌ផ្ទៃមេឃ ដែលសន្ធឹងស្កុកស្កឹងនៅខាងមុខ ៗ រថយន្តគ្មានរលាក់សោះ មានតែហើបឡើង ឬ បន្ទាបចុះតាមលំអានខ្ពស់ទាប ៗ ហើយបត់បែនទៅតាមបង្អើះក្នុំ ។

រថយន្តចុះអំពីចង្កេះភ្នំបន្តិចម្ដងៗ ងាកខាងត្បូងហើយសសៀរយឺតៗ ទៅតាមឆ្នេរសមុទ្រដែលនៅជាប់នឹងជើងភ្នំ ។ នេះឯង កែបឆ្នេរផលសា របស់ប្រទេសខ្មែរ ។

អុឹម - ឈួជើត

## ក–ពន្យល់ពាក្យ

ឆ្នេរផលសា : មាត់សមុទ្រ (ទីនេះ) (Plage) ។

កម្រាលប្រាក់ : ផ្លូវក្រាលដ៏ស្អាតជេន ។

តាមលំអាន : តាមលំដាប់លំដោយ ។

## ១- អក្ខរាវិរុទ្ធ

ភេទ (សរសេរប្រកបនឹង ទ)

ស្គុកស្គម (សរសេរ ម ជើង ក នៅចុង)

គម្ពោធ (ប្រយ័ត្នកុំសរសេរ កំពោធ ឬ កំប៉ូត)

ស្រគាំ (កុំសរសេរស្រគំ)

សនធាន (ពុំសរសេរត្រួតលើគ្នាជាសន្ធាន)

សសៀ (ឥតមាន រ ទេ)

ឆ្នេរ (មាន រ នៅចុង)

សមុទ្រ ឬ សមុទ្ទ (ដាក់បានពីរយ៉ាង)

គ- ពាក្យស័ព្ទ

ពាំង កិ. (ដើមឈើបាក់មកពាំងផ្លូវ)

ពាំង ន. (ដើមពាំងដុះកណ្ដាលស្រះ)

បត់ កិ. (រថយន្ដបត់ទៅខាងលិច)

បទ ន. (គេច្រៀងបទនគររាជ)

[illegible] ?

[illegible]

[illegible]

[illegible]

Tùng

[illegible] - [illegible]

រោគ ផ្ដាសាយ Grippe

〃 គ្រុន Fièvre

〃 [illegible] Dysenterie

តម្លៃ ២០ រ,០០